ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រ

# ស្តីពី

# ការអនុវត្តគោលនយោបាយ

# «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

# (២០២៤-២០២៨)

**ក្រសួងមហាផ្ទៃ**

ខែកក្កដា ឆ្នាំ២០២៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ......០០៤......ស.ក...

# ផែនការយុទ្ធសាស្ត្រ
# ស្តីពី
# ការអនុវត្តគោលនយោបាយ
# «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
# (២០២៤-២០២៨)

**ឆ្នាំ២០២៤**

# អារម្ភកថា

ក្រសួងមហាផ្ទៃ ជាសេនាធិការជូនរាជរដ្ឋាភិបាលដោយត្រូវសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ព្រមទាំងដឹកនាំ តាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ដោយមានលេខាធិការដ្ឋាន គ.ភ.ឃ.ស. ជាជំនួយការដែលបានបង្កើតឡើងក្នុងខែកក្កដា ឆ្នាំ២០២២ ។

ផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ពីឆ្នាំ ២០២៤ដល់ឆ្នាំ២០២៨ បង្ហាញអំពីជំហានជាយុទ្ធសាស្ត្រ ដែលក្រសួងមហាផ្ទៃត្រូវអនុវត្តក្នុងរយៈពេល៥ ឆ្នាំខាងមុខ ដើម្បីបំពេញតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការអនុវត្ត គ.ភ.ឃ.ស.។ ផែនការនេះ បង្ហាញពីការប្តេជ្ញាចិត្តរបស់ក្រសួងមហាផ្ទៃក្នុងការសហការ សម្របសម្រួល តាមដានត្រួតពិនិត្យ វាយតម្លៃ និងការគាំទ្រក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ភាគីពាក់ព័ន្ធនានាក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

ផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបាន រៀបចំឡើង តាមរយៈការប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធនានា និងដោយផ្អែកលើឯកសារសំខាន់ៗមួយ ចំនួន មានដូចជាគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាល (២០២១) យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាល (២០២៣) ផែនការយុទ្ធសាស្ត្ររបស់ក្រសួង មហាផ្ទៃពីឆ្នាំ២០២៤-២០២៨ (២០២៤) ព្រមទាំងលិខិតបទដ្ឋាន សេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹង យន្តការតួនាទី ភារកិច្ច និងនីតិវិធីសម្រាប់អនុវត្ត គ.ភ.ឃ.ស.។

ផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» គឺជាផែនទី បង្ហាញផ្លូវសម្រាប់ក្រសួងមហាផ្ទៃក្នុងការសហការ សម្របសម្រួល តាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្តល់ ការគាំទ្រដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ភាគីពាក់ព័ន្ធនានា ដើម្បីធានាការចាត់តាំងអនុវត្ត គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ប្រកបដោយប្រសិទ្ធភាព។ ផែនការនេះរួមបញ្ចូលផ្នែក សំខាន់ៗមានដូចជា ការតម្រង់ទិសផ្នែកគោលនយោបាយរបស់រាជរដ្ឋាភិបាល ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ ដើម្បីសម្រេចគោលដៅនីមួយៗរួមបញ្ចូលទាំងលទ្ធផលរំពឹងទុក និងសូចនាករ សំខាន់ៗដែលត្រូវសម្រេចក្នុងឆ្នាំនីមួយៗ។

ក្នុងនាមក្រសួងមហាផ្ទៃ និងក្នុងតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្រប សម្រួលការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃ ខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួង ស្ថាប័ន លេខាធិការដ្ឋាន គ.ភ.ឃ.ស. រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានាដែលបានផ្តល់ការគាំទ្រ ព្រមទាំងចូលរួមសហការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការ

ការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ក៏ដូចជាការអនុវត្តគោលនយោបាយនេះក្នុងរយៈពេលកន្លងមកប្រកបដោយជោគជ័យ និងសម្រេចលទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់។

ក្រសួងមហាផ្ទៃ សូមស្វាគមន៍នូវរាល់មតិយោបល់នានាក្នុងន័យស្ថាបនារបស់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីកែលម្អផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់ក្រសួងមហាផ្ទៃនេះឱ្យកាន់តែល្អប្រសើរ។

ខ្ញុំសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួង ស្ថាប័ន លេខាធិការដ្ឋាន គ.ក.ឃ.ស. រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសាធារណជន នឹងបន្តកិច្ចសហការ ផ្តល់ការគាំទ្រ និងចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់ក្រសួងមហាផ្ទៃ ក៏ដូចជាការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាលកាន់តែសកម្ម ឱ្យទទួលបានជោគជ័យថ្មីៗបន្ថែមទៀត ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ ព្រមទាំងរួមចំណែកក្នុងការអនុវត្តប្រកបដោយជោគជ័យនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា៕

ថ្ងៃ.................................... ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អគ្គបណ្ឌិតសភាចារ្យ ស សុខា**

# មាតិកា


អារម្ភកថា ... i

បញ្ជីតារាង ... v

បញ្ជីអក្សរកាត់ ... vi

១. សេចក្ដីផ្ដើម ... ១

១.១. សាវតារ ... ១

១.២. សមិទ្ធផល ... ២

១.៣. បញ្ហាប្រឈម ... ៣

១.៤. ដំណើរការរៀបចំ ... ៤

១.៥. រចនាសម្ព័ន្ធឯកសារ ... ៤

២. ក្របខណ្ឌយុទ្ធសាស្ត្រនៃផែនការ ... ៥

២.១. បេសកកម្ម ... ៥

២.២. ការតម្រង់ទិសផ្នែកគោលនយោបាយ ... ៥

២.៣. ចក្ខុវិស័យ ... ៥

២.៤. គោលបំណង ... ៦

២.៥. គោលដៅ ... ៦

៣. វិសាលភាព ... ៦

៤. យុទ្ធសាស្ត្រសម្រាប់ការអនុវត្តផែនការ ... ៦

គោលដៅទី១ ៖ **កសាង និងពង្រឹងសមត្ថភាពស្ថាប័ន និងបុគ្គលិក** ... ៧

យុទ្ធសាស្ត្រទី ១.១ ៖ ពង្រឹងយន្តការដឹកនាំ សម្របសម្រួល និងអនុវត្ត គ.ភ.ឃ.ស. ... ៧

យុទ្ធសាស្ត្រទី ១.២ ៖ រៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត សេចក្ដីណែនាំ និងឯកសារ បច្ចេកទេសនានា ពាក់ព័ន្ធនឹងការអនុវត្ត គ.ភ.ឃ.ស ... ១២

យុទ្ធសាស្ត្រទី ១.៣ ៖ លើកកម្ពស់ចំណេះដឹង និងសមត្ថភាពអំពី គ.ភ.ឃ.ស. ... ១៣

គោលដៅទី២ ៖ **លើកកម្ពស់ការអនុវត្ត គ.ភ.យ.ស.** ..... ១៥

យុទ្ធសាស្ត្រទី ២.១ ៖ គោលនយោបាយ គ.ភ.យ.ស. ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព..... ១៥

យុទ្ធសាស្ត្រទី ២.២ ៖ លើកកម្ពស់ភាពជាដៃគូក្នុងការអនុវត្ត គ.ភ.យ.ស..... ១៩

យុទ្ធសាស្ត្រទី ២.៣ ៖ ជំរុញចលនាប្រឡងប្រណាំងស្តីពីការអនុវត្ត គ.ភ.យ.ស. ..... ២០

យុទ្ធសាស្ត្រទី ២.៤ ៖ ពង្រឹងប្រព័ន្ធទិន្នន័យសម្រាប់អនុវត្ត និងគ្រប់គ្រង គ.ភ.យ.ស. តាមរយៈប្រព័ន្ធឌីជីថល..... ២២

៥. យន្តការសម្រាប់ការអនុវត្ត..... ២៤

៦. ការត្រួតពិនិត្យ និងការវាយតម្លៃ..... ២៤

៦.១. ការរៀបចំទិន្នន័យដើមគ្រា..... ២៥

៦.២. ការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ..... ២៥

៦.៣. ការវាយតម្លៃពាក់កណ្តាលផែនការ..... ២៥

៦.៤. ការវាយតម្លៃចុងបញ្ចប់នៃផែនការ..... ២៦

៧. ការគ្រប់គ្រងហានិភ័យ..... ២៦

៨. គម្រោងថវិកា..... ២៧

៩. សេចក្តីសន្និដ្ឋាន..... ២៨

**ឧបសម្ព័ន្ធ**

១. ក្របខ័ណ្ឌលទ្ធផលនៃផែនការយុទ្ធសាស្ត្រ..... ៣០

២. ថវិកាប៉ាន់ស្មានតាមយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុកពីឆ្នាំ២០២៤-២០២៨..... ៣៧

៣. រចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ភ.យ.ស.. ..... ៤០

# បញ្ជីតារាង

តារាងទី១ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.១...........................................៧
តារាងទី២ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.២. ..........................................៨
តារាងទី៣ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៣.......................................... ៩
តារាងទី៤ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៤.........................................១០
តារាងទី៥ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៥.........................................១០
តារាងទី៦ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៦........................................ ១១
តារាងទី៧ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៧. ........................................១២
តារាងទី៨ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.២.១. ....................................... ១៣
តារាងទី៩ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.២.២. ....................................... ១៣
តារាងទី១០ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.៣.១......................................១៤
តារាងទី១១ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.៣.២. ....................................១៥
តារាងទី១២ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.៣.៣......................................១៥
តារាងទី១៣ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.១.១. ....................................១៦
តារាងទី១៤ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.១.២. ................................... ១៧
តារាងទី១៥ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.១.៣. ....................................១៨
តារាងទី១៦ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.១.៤......................................១៨
តារាងទី១៧ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.២.១. ................................... ១៩
តារាងទី១៨ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.២.២. ....................................២០
តារាងទី១៩ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.៣.១. ....................................២១
តារាងទី២០ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.៣.២......................................២២
តារាងទី២១ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.៤.១. ................................... ២៣
តារាងទី២២ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.៤.២..................................... ២៣
តារាងទី២៣ ៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ.......................................................២៦
តារាងទី២៤ ៖ ថវិកាប៉ាន់ស្មាននៃផែនការយុទ្ធសាស្រ្ត...............................................................២៨

# បញ្ជីអក្សរកាត់

| **អក្សរកាត់** | **ពាក្យពេញ** |
|---|---|
| គ.ភ.ឃ.ស. | គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ជ.គ.ម. | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |

# ១. សេចក្តីផ្តើម

## ១.១. សាវតារ

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» លេខ០១ គនប របស់រាជរដ្ឋាភិបាល ត្រូវបានដាក់ចេញនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ក្នុងគោលបំណងបន្តកសាង និងពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីគ្រោះមហន្តរាយនិងជំងឺឆ្លងរាតត្បាត នៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ ព្រមទាំងរួមចំណែកអនុវត្តដោយជោគជ័យនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា។

រាជរដ្ឋាភិបាល បានចាត់តាំងក្រសួងមហាផ្ទៃធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលដោយត្រូវសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ព្រមទាំងដឹកនាំ តាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ដើម្បីអនុវត្ត គ.ភ.ឃ.ស. ប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលក៏បានណែនាំឱ្យក្រសួងមហាផ្ទៃរៀបចំលេខាធិការដ្ឋានមួយ ដើម្បីជួយការងារប្រចាំថ្ងៃរបស់ខ្លួន។ ក្នុងន័យនេះ លេខាធិការដ្ឋាន គ.ភ.ឃ.ស. ត្រូវបានបង្កើតក្នុងខែកក្កដា ឆ្នាំ២០២២ និងមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែង និងផែនការរយៈពេលមធ្យមស្តីពីការអនុវត្តគោល-នយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- រៀបចំ និងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់លេខាធិការដ្ឋានស្តីពីការសហការសម្របសម្រួល តាមដាន ត្រួតពិនិត្យ និងដាស់តឿនក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សហការរៀបចំគោលនយោបាយ សេចក្តីណែនាំនានា និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សហការ និងផ្តល់អនុសាសន៍ ក្នុងការអនុវត្តលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- ផ្សព្វផ្សាយអំពីគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សម្របសម្រួល តាមដាន និងផ្តល់ការគាំទ្របច្ចេកទេសដល់ស្ថាប័ននានា ក្នុងការអនុវត្តគោល-នយោបាយ
- សហការ ដឹកនាំ និងផ្តល់អនុសាសន៍ក្នុងការអនុវត្តចលនាប្រឡងប្រណាំងអំពីការអនុវត្តគោល-នយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

- កៀរគរការចូលរួម និងការគាំទ្រពីដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជននានាក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- បូកសរុប និងរៀបចំរបាយការណ៍នានាជូនក្រសួងមហាផ្ទៃ អំពីលទ្ធផលនៃការអនុវត្តគោល-នយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។
- បំពេញភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងឆ្នាំ២០២៣ រាជរដ្ឋាភិបាលអាណត្តិទី៧ដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលជាមូលដ្ឋានសម្រាប់ក្រសួងមហាផ្ទៃក្នុងការបំពេញតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល ដើម្បីធានាដល់ការបន្តរក្សាឱ្យបានរឹងមាំនូវសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម។

ទន្ទឹមគ្នានេះ នៅដើមឆ្នាំ២០២៤ ក្រសួងមហាផ្ទៃក៏បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមពីឆ្នាំ២០២៤ដល់ឆ្នាំ២០២៨ ក្នុងគោលបំណងលើកកម្ពស់ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់ថ្នាក់ ព្រមទាំងការពង្រឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសំណើសំណូមពរចាំបាច់របស់ប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាប្រឈមប្រកបដោយប្រសិទ្ធភាព គុណភាព គណនេយ្យភាព តម្លាភាព យុត្តិធម៌ បរិយាបន្ន និងសមធម៌សង្គម។

ដើម្បីធានាការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃក្នុងតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការអនុវត្ត គ.ភ.ឃ.ស. ចាំបាច់ត្រូវរៀបចំផែនការយុទ្ធសាស្ត្រមួយ សម្រាប់ធ្វើជាផែនទីបង្ហាញផ្លូវក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយនេះ ប្រកបដោយប្រសិទ្ធភាព និងសម្រេចបាននូវគោលបំណងគ្រោងទុក។

### ១.២. សមិទ្ធផល

ជារួម ការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» បានរួមចំណែកយ៉ាងសំខាន់ក្នុងការធានាបាននូវប្រក្រតីភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយភាពសុខសាន្ត។ ក្នុងន័យនេះ ការផ្តល់សេវាសាធារណៈ ការបង្ក្រាបបទល្មើសគ្រប់ប្រភេទ ការអនុវត្តច្បាប់ចរាចរណ៍ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ការបង្ក្រាបសកម្មភាពក្មេងទំនើង ការផ្តល់អន្តរាគមន៍គ្រោះថ្នាក់អគ្គិភ័យ និងការសង្គ្រោះជនរងគ្រោះនានា ត្រូវបានលើកកម្ពស់ យកចិត្តទុកដាក់ ជំរុញ និងពង្រឹងការអនុវត្តជាប្រចាំ។ ជាក់ស្តែង ចលនាប្រឡងប្រណាំងក្នុងការចាត់តាំងអនុវត្ត គ.ភ.ឃ.ស. ពាក់ព័ន្ធនឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ មានឃុំ សង្កាត់ចំនួនជាមធ្យម ៧០% នៃឃុំ សង្កាត់សរុបទូទាំងប្រទេស ចំនួន១.៦៥៣ ទទួលបានចំណាត់ថ្នាក់លេខ១ជារៀងរាល់ឆ្នាំ។

ជាមួយគ្នានេះដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ក្រសួងមហាផ្ទៃបានសម្រេចនូវលទ្ធផល

សំខាន់ៗមួយចំនួនទៀត មានដូចជាបានបង្កើត និងដាក់ឱ្យដំណើរការនូវលេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្នុងខែកក្កដា ឆ្នាំ២០២២ ដើម្បីជួយក្រសួងមហាផ្ទៃ បំពេញតួនាទី និងភារកិច្ចប្រចាំថ្ងៃធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការចាត់តាំងអនុវត្ត គ.ភ.ឃ.ស.។ ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន សម្រាប់គាំទ្រការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**។ ទន្ទឹមនេះ ក្រសួងក៏បានរៀបចំ និងដាក់ចេញសៀវភៅណែនាំស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» នៅខែមីនា ឆ្នាំ២០២៣ ព្រមទាំងបានផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទូទាំងប្រទេស។

### ១.៣. បញ្ហាប្រឈម

ជាមួយនឹងសមិទ្ធផលដែលទទួលបានខាងលើ ការអនុវត្ត គ.ភ.ឃ.ស. បានជួបប្រទះបញ្ហាសំខាន់ៗមួយចំនួនដែលត្រូវបន្តយកចិត្តទុកដាក់ និងដោះស្រាយក្នុងផែនការយុទ្ធសាស្រ្តស្តីពីការអនុវត្ត គ.ភ.ឃ.ស. រួមមានដូចខាងក្រោម ៖

- ក្រសួង ស្ថាប័នភាគច្រើនមិនទាន់បានបង្កើតក្រុមការងារ ដើម្បីទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តលក្ខណសម្បត្តិនានានៃ គ.ភ.ឃ.ស. ដែលពាក់ព័ន្ធនឹងជំនាញរបស់ក្រសួង ស្ថាប័ននីមួយៗ
- លេខាធិការដ្ឋាន គ.ភ.ឃ.ស. ជាស្ថាប័នថ្មី ខ្វះធនធានមនុស្ស ជាពិសេសខ្វះមន្ត្រីបច្ចេកទេស ខ្វះធនធានហិរញ្ញវត្ថុ និងសមត្ថភាពរបស់មន្ត្រីនៅមានកម្រិតក្នុងការសម្របសម្រួល និងអនុវត្ត គ.ភ.ឃ.ស.។
- នៅថ្នាក់ក្រោមជាតិ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់មួយចំនួន អនុវត្តគ.ភ.ឃ.ស.ពុំទាន់ទូលំទូលាយ និងស៊ីជម្រៅនៅឡើយ។ ជាមួយគ្នានេះដែរក៏មានការខ្វះខាតកម្លាំងនៅតាមប៉ុស្តិ៍នគរបាលរដ្ឋបាលមួយចំនួន គួបផ្សំមធ្យោបាយ ឧបករណ៍ សម្ភារ ថវិកា ប្រេងឥន្ធនៈ ពុំទាន់ឆ្លើយតបទៅនឹងការអនុវត្តការងារជាក់ស្តែង ពិសេសការងារតាមទម្រង់ «ការងារនគរបាល និងសហគមន៍»។
- គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុងឆ្នាំ២០២១ រួមបញ្ចូលលក្ខណសម្បត្តិថ្មីមួយចំនួនដូចជា លើកកម្ពស់ការផ្តល់សេវាសាធារណៈ ការលើកកម្ពស់អនាម័យ បរិស្ថាន និងសោភណភាពសហគមន៍ ការដោះស្រាយវិវាទនៅមូលដ្ឋាន និងការទប់ស្កាត់ជំងឺឆ្លងរាតត្បាតកាចសាហាវនានា ដែលចាំបាច់ ត្រូវយកចិត្តទុកក្នុងការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ សៀវភៅណែនាំ ការផ្សព្វផ្សាយ ការអភិវឌ្ឍសមត្ថភាព...ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាន គ.ភ.ឃ.ស. និងភាគីពាក់ព័ន្ធផ្សេងទៀត

- គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាល ត្រូវចូលរួមអនុវត្តដោយប្រជាពលរដ្ឋ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា។ អាស្រ័យហេតុនេះ ក្រសួងមហាផ្ទៃត្រូវមាន យុទ្ធសាស្ត្រសមស្រប ដើម្បីអនុវត្ត គ.ភ.ឃ.ស. ក្នុងភាពជាដៃគូជាមួយប្រជាពលរដ្ឋ និងស្ថាប័នទាំងនេះ។
- គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាលមិនទាន់យល់ដឹង និងជ្រួតជ្រាបដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់ និងនៅគ្រប់ទីកន្លែង។

## ១.៤. ដំណើរការរៀបចំ

ផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់ក្រសួងមហាផ្ទៃ ត្រូវបានចាប់ផ្តើមរៀបចំក្នុងខែឧសភា ឆ្នាំ២០២៣ ដល់ខែកក្កដា ឆ្នាំ២០២៤ ដោយក្រុមការងាររបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. ស្ថិតក្រោមការដឹកនាំ ការសម្របសម្រួល និងការតម្រង់ទិសជាប្រចាំរបស់ឯកឧត្តមសន្តិបណ្ឌិតរដ្ឋលេខាធិការប្រចាំការ ឯកឧត្តមរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋាន គ.ភ.ឃ.ស. ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមានការគាំទ្រផ្នែកបច្ចេកទេសពីទីប្រឹក្សាជាតិចំនួនមួយរូបដែលគាំទ្រដោយអង្គការ UNICEF។ ផែនការនេះត្រូវបានរៀបចំដោយផ្អែកលើគោលនយោបាយបាយ លិខិតបទដ្ឋានគតិយុត្តសេចក្តីណែនាំ និងសៀវភៅណែនាំនានាដែលពាក់ព័ន្ធនឹង គ.ភ.ឃ.ស. និងតាមរយៈដំណើរការដែលមានការចូលរួម និងការប្រឹក្សាយោបល់ជាមួយអង្គភាពចំណុះក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្ត និងក្រសួងស្ថាប័នពាក់ព័ន្ធនានា។

## ១.៥. រចនាសម្ព័ន្ធឯកសារ

ឯកសារផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» រួមមាន ៨ ផ្នែកដូចមានសង្ខេបខាងក្រោម ៖

ផ្នែកទី១ ជាសេចក្តីផ្តើមដែលរៀបរាប់អំពីសាវតារ សមិទ្ធផល បញ្ហាប្រឈម និងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ។

ផ្នែកទី២ ជាក្របខណ្ឌយុទ្ធសាស្ត្រកំណត់អំពីបេសកកម្ម ការតម្រង់ទិសផ្នែកគោលនយោបាយ ចក្ខុវិស័យ គោលបំណង និងគោលដៅរបស់ផែនការយុទ្ធសាស្ត្រ។

ផ្នែកទី៣ គឺជាវិសាលភាពនៃផែនការយុទ្ធសាស្ត្រ។

ផ្នែកទី៤ ជាផ្នែកមួយដ៏សំខាន់ដែលរៀបរាប់លម្អិតអំពីយុទ្ធសាស្ត្រនានាដែលត្រូវអនុវត្តរួមបញ្ចូលទាំងលទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សូចនាករនិងចំណុចដៅ និងស្ថាប័នទទួលខុសត្រូវ។

ផ្នែកទី៥ ជាយន្តការសម្រាប់អនុវត្តដែលបរិយាយអំពីស្ថាប័នសំខាន់ៗដែលទទួលខុសត្រូវក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រ។

ផ្នែកទី៦ គឺជាការត្រួតពិនិត្យ និងការវាយតម្លៃផែនការយុទ្ធសាស្ត្រដែលរួមមាន ការរៀបចំទិន្នន័យដើមគ្រា ការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ ការវាយតម្លៃពាក់កណ្តាលផែនការ និងការវាយតម្លៃចុងបញ្ចប់ ផែនការ។

ផ្នែកទី៧ ជាគម្រោងថវិកាដែលប៉ាន់ស្មានចំណាយសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រ។

ផ្នែកទី៨ ជាសេចក្តីសន្និដ្ឋាន ដែលបរិយាយអំពីលទ្ធផលសំខាន់ៗនៃផែនការយុទ្ធសាស្ត្រដែលត្រូវសម្រេច និងតម្រូវការចំបាច់ ដើម្បីជានាការសម្រេចបាននូវគោលដៅ គោលបំណង និងចក្ខុវិស័យរបស់ផែនការយុទ្ធសាស្ត្រ។

## ២. ក្របខណ្ឌយុទ្ធសាស្ត្រនៃផែនការ

### ២.១. បេសកកម្ម

ក្រសួងមហាផ្ទៃ ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងមានបេសកកម្មសំខាន់ក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ព្រមទាំងដឹកនាំ តាមដាន ត្រួតពិនិត្យ និងរំលឹកដាស់តឿនគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ក្នុងការចាត់តាំង និងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ប្រកបដោយប្រសិទ្ធភាព ស្របតាមតួនាទី និងភារកិច្ចរបស់ខ្លួន។

### ២.២. ការតម្រង់ទិសផ្នែកគោលនយោបាយ

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាលបានកំណត់យ៉ាងច្បាស់អំពីគុណតម្លៃនៃ **សន្តិភាពស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុខុមាលភាព និងសេវាសាធារណៈល្អ** ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀតឱ្យមានការរីកចម្រើន ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ ផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវអនុវត្តដោយប្រកាន់ភ្ជាប់នូវគុណតម្លៃទាំង៥នេះ។

### ២.៣. ចក្ខុវិស័យ

ដើម្បីរួមចំណែកសម្រេចបានគោលបំណងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងការប្រែក្លាយប្រទេសកម្ពុជា ឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ចក្ខុវិស័យនៃផែនការយុទ្ធសាស្ត្រស្តីពីគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» គឺ **ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈប្រកបដោយគុណភាព តម្លាភាព បរិយាប័ន្នសង្គម និងរស់នៅប្រកបដោយសុវត្ថិភាព ផាសុកភាព និងសុខដុមរមនាក្នុងសហគមន៍ដែលមានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម បរិស្ថាន ធនធានធម្មជាតិ និងអនាម័យល្អប្រសើរ។**

### ២.៤. គោលបំណង

ផែនការយុទ្ធសាស្ត្រស្ដីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» មានគោលបំណង **លើកកម្ពស់ការផ្ដល់សេវាសាធារណៈ ពង្រឹងសន្តិសុខ សណ្ដាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់នានា ដែលបណ្ដាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ** ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅការបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ ព្រមទាំងរួមចំណែកអនុវត្តដោយជោគជ័យនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា។

### ២.៥. គោលដៅ

ដើម្បីធានាការសម្រេចបាននូវគោលបំណង និងចក្ខុវិស័យខាងលើ ផែនការយុទ្ធសាស្ត្រស្ដីពីការអនុវត្ត គ.ភ.ឃ.ស. មានគោលដៅជាក់លាក់ដូចខាងក្រោម ៖

**១. កសាង និងពង្រឹងសមត្ថភាពស្ថាប័ន និងបុគ្គលិកនៃលេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ភាគីពាក់ព័ន្ធនានាក្នុងការសម្របសម្រួល តាមដាន និងអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹង គ.ភ.ឃ.ស.។**

**២. លើកកម្ពស់ការអនុវត្ត គ.ភ.ឃ.ស. ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព មានសមភាពយេនឌ័រ បរិយាប័ន្ន សមធម៌សង្គម និងក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។**

## ៣. វិសាលភាព

ស្របជាមួយនឹងគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ផែនការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងជាផែនទីបង្ហាញផ្លូវសម្រាប់ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការអនុវត្តលក្ខណសម្បត្តិទាំង ៧ នៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ពីឆ្នាំ២០២៤ដល់ឆ្នាំ២០២៨។

## ៤. យុទ្ធសាស្ត្រសម្រាប់ការអនុវត្តផែនការ

ដើម្បីសម្រេចបានគោលដៅ គោលបំណង និងចក្ខុវិស័យខាងលើ ផែនការយុទ្ធសាស្ត្រស្ដីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ របស់ក្រសួងមហាផ្ទៃ បានកំណត់យុទ្ធសាស្ត្រសំខាន់ៗចំនួន ៧ សម្រាប់អនុវត្ត ដែលយុទ្ធសាស្ត្រនីមួយៗរួមបញ្ចូលនូវលទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សូចនាករ និងចំណុចដៅដែលត្រូវសម្រេចតាមឆ្នាំនីមួយៗ ដូចមានបរិយាយខាងក្រោម ៖

**គោលដៅទី១ ៖**

**កសាង និងពង្រឹងសមត្ថភាពស្ថាប័ន និងបុគ្គលិកនៃលេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ភាគីពាក់ព័ន្ធនានាក្នុងការសម្របសម្រួល តាមដាន និងអនុវត្ត តួនាទី ភារកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹង គ.ភ.ឃ.ស.។**

**យុទ្ធសាស្ត្រទី ១.១ ៖ ពង្រឹងយន្តការដឹកនាំ សម្របសម្រួល និងអនុវត្ត គ.ភ.ឃ.ស.**

លទ្ធផលរំពឹងទុក ១.១.១ ៖ ការបំពេញតួនាទី និងភារកិច្ចរបស់ក្រសួងមហាផ្ទៃ ជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានពង្រឹង

ក្រសួងមហាផ្ទៃ ជាសេនាធិការជូនរាជរដ្ឋាភិបាល និងមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំសម្របសម្រួលការអនុវត្ត គ.ភ.ឃ.ស. ដោយសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា។

ដើម្បីជួយក្រសួងមហាផ្ទៃក្នុងការអនុវត្តតួនាទីនេះប្រកបដោយប្រសិទ្ធភាព សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តដោយលេខាធិការដ្ឋាន គ.ភ.ឃ.ស. រួមមាន ៖

- ជួយក្រសួងមហាផ្ទៃក្នុងការរៀបចំកិច្ចប្រជុំជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានាស្តីពីការអនុវត្ត គ.ភ.ឃ.ស.
- ជួយក្រសួងមហាផ្ទៃក្នុងការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានា ដែលពាក់ព័ន្ធនឹងការអនុវត្ត គ.ភ.ឃ.ស.
- ជួយក្រសួងមហាផ្ទៃក្នុងការបូកសរុប និងរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ និងពិភាក្សាក្នុងសន្និបាត ប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ
- ជួយក្រសួងមហាផ្ទៃក្នុងការរៀបចំរបាយការណ៍ជាទៀងទាត់ជូនរាជរដ្ឋាភិបាលអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត គ.ភ.ឃ.ស.។

**តារាងទី១ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.១.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ចំនួនកិច្ចប្រជុំដែលបានរៀបចំ | ២ | ២ | ២ | ២ | ២ |
| ២ | ការរៀបចំរបាយការណ៍ជូនក្រសួងមហាផ្ទៃ | ១ | ១ | ១ | ១ | ១ |
| ៣ | ការរៀបចំរបាយការណ៍ជូនរាជរដ្ឋាភិបាល | ១ | ១ | ១ | ១ | ១ |

លទ្ធផលរំពឹងទុក ១.១.២ ៖ ការបំពេញតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. ដើម្បីជួយក្រសួងមហាផ្ទៃអនុវត្ត គ.ភ.ឃ.ស. ត្រូវបានពង្រឹង

លេខាធិការដ្ឋាន គ.ភ.ឃ.ស. មានភារកិច្ចយ៉ាងសំខាន់ក្នុងការជួយគាំទ្រក្រសួងមហាផ្ទៃដឹកនាំ និងសម្របសម្រួលអនុវត្ត គ.ភ.ឃ.ស.។ ក្នុងន័យនេះ លេខាធិការដ្ឋាន គ.ភ.ឃ.ស. មានភារកិច្ចយ៉ាងសំខាន់

ក្នុងការតាមដាន សហការ គាំទ្រក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន ភាគីពាក់ព័ន្ធនានា និងតាមដាន ត្រួតពិនិត្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្ត គ.ភ.ឃ.ស. ប្រកបដោយប្រសិទ្ធភាព។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ភ.ឃ.ស. ត្រូវមានធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងសមត្ថភាពសមស្រប ដើម្បីបំពេញភារកិច្ចនេះដោយជោគជ័យ។

ដើម្បីសម្រេចបាននូវភារកិច្ចនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំក្រុមជំនួយការដែលមានសមាជិកចំនួនពី ៤-៥ នាក់ ដើម្បីជួយថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្នុងការបំពេញការងារប្រចាំថ្ងៃ
- រៀបចំក្រុមការងារបច្ចេកទេសដែលមានសមាជិកចំនួនពី ៥-៧ នាក់ ដើម្បីជួយក្រុមនីមួយៗចំណុះលេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្នុងការបំពេញការងារប្រចាំថ្ងៃ
- ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងលេខាធិការដ្ឋាន គ.ភ.ឃ.ស. ជាទៀងទាត់ ដើម្បីរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្ដីពីការអនុវត្ត គ.ភ.ឃ.ស.
- ជំរុញក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធក្នុងការរៀបចំក្រុមការងារសម្រាប់ទំនាក់ទំនងជាមួយលេខាធិការដ្ឋាន គ.ភ.ឃ.ស.
- រៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា ដើម្បីត្រួតពិនិត្យពីវឌ្ឍនភាព និងសម្របសម្រួលដោះស្រាយបញ្ហាប្រឈមនានានៃការអនុវត្ត គ.ភ.ឃ.ស.
- សហការសម្របសម្រួល និងអភិវឌ្ឍសមត្ថភាពក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានាក្នុងការអនុវត្ត គ.ភ.ឃ.ស.
- សហការរៀបចំគោលនយោបាយ លិខិតបទដ្ឋាន និងសេចក្ដីណែនាំនានាពាក់ព័ន្ធនឹងការអនុវត្ត គ.ភ.ឃ.ស.
- សហការផ្សព្វផ្សាយ និងរៀបចំសកម្មភាពអភិវឌ្ឍសមត្ថភាពអំពី គ.ភ.ឃ.ស. ដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា។

**តារាងទី២ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.២.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំក្រុមជំនួយការថ្នាក់ដឹកនាំរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. | ១ | | | | |
| ២ | ការរៀបចំក្រុមបច្ចេកទេសសម្រាប់ក្រុមនីមួយៗចំណុះលេខាធិការដ្ឋាន | ១ | | | | |
| ៣ | ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់លេខាធិការដ្ឋាន | | ១ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | កិច្ចប្រជុំរបស់លេខាធិការដ្ឋាន | ៤ | ៤ | ៤ | ៤ | ៤ |
| ៥ | កិច្ចប្រជុំជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ៤ | ៤ | ៤ | ៤ | ៤ |
| ៦ | ចំនួនលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអនុវត្ត គ.ភ.ឃ.ស. ដែលបានរៀបចំ | ២ | ២ | ២ | ២ | ២ |
| ៧ | ចំនួនវគ្គអភិវឌ្ឍសមត្ថភាពដែលបានរៀបចំដល់ភាគីពាក់ព័ន្ធនានា | ៣ | ៣ | ៣ | ៣ | ៣ |

លទ្ធផលរំពឹងទុក ១.១.៣ ៖ ក្រុមការងារ គ.ភ.ឃ.ស. របស់ក្រសួង ស្ថាប័ន ត្រូវបានបង្កើត និងដំណើរការ

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាល លេខ០១ គនប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ តម្រូវឱ្យក្រសួង ស្ថាប័នត្រូវបង្កើតក្រុមការងារ ដើម្បីជួយក្រសួងស្ថាប័នក្នុងការអនុវត្ត គ.ភ.ឃ.ស.។

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះរួមមាន ៖

- រៀបចំលក្ខខណ្ឌការងាររបស់ក្រុមការងារអនុវត្ត គ.ភ.ឃ.ស. របស់ក្រសួង ស្ថាប័ន
- ជូនដំណឹងដល់ក្រសួង ស្ថាប័នក្នុងការបង្កើតក្រុមការងារអនុវត្ត គ.ភ.ឃ.ស.
- តាមដាន សម្របសម្រួល និងគាំទ្រក្រសួង ស្ថាប័នក្នុងការបង្កើតក្រុមការងារអនុវត្ត គ.ភ.ឃ.ស.
- គាំទ្រ និងអភិវឌ្ឍសមត្ថភាពក្រុមការងារ។

**តារាងទី៣ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៣.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំលក្ខខណ្ឌក្រុមការងារ | ១ | | | | |
| ២ | ការបង្កើតក្រុមការងារ | ១ | | | | |
| ៣ | ការអភិវឌ្ឍសមត្ថភាពដល់ក្រុមការងារ | ២ | ២ | ២ | ២ | ២ |

លទ្ធផលរំពឹងទុក ១.១.៤ ៖ ការបំពេញតួនាទី និងភារកិច្ចរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានពង្រឹង

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានតួនាទីសំខាន់ក្នុងការដឹកនាំ សម្របសម្រួល និងដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការអនុវត្ត គ.ភ.ឃ.ស. ដោយសហការជាមួយសមត្ថកិច្ច និងភាគីពាក់ព័ន្ធនានា។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- ផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្ត គ.ភ.ឃ.ស. និងលិខិតបទដ្ឋានពាក់ព័ន្ធនានា
- តាមដាន និងគាំទ្រគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន

- សិក្សាអំពីការកែសម្រួលសមាសភាព និងភារកិច្ចរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដោយបញ្ចូលតំណាងមកពីមន្ទីរអង្គភាពជំនាញ និងភាគីពាក់ព័ន្ធនានា ស្របតាមលក្ខណសម្បត្តិ គ.ភ.ឃ.ស.។

**តារាងទី៤ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៤.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំដល់គណៈបញ្ជាការឯកភាពរដ្ឋបាល | ៣ | ៣ | ៣ | ៣ | ៣ |
| ២ | ភាគរយគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ខេត្តដែលបានចុះគាំទ្រ | ៥០% | ៧០% | ៧០% | ៧០% | ៧០% |
| ៣ | ភាគរយគណៈបញ្ជាការឯកភាពរដ្ឋបាលដែលមានពិនិត្យ និងកែសម្រួលសមាសភាព | ៣០% | ៥០% | ១០០% | ១០០% | ១០០% |

### លទ្ធផលរំពឹងទុក ១.១.៥ ៖ ការបំពេញតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវបានពង្រឹង

លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានភារកិច្ចសំខាន់ក្នុងការជួយគណៈបញ្ជាការឯកភាពរដ្ឋបាលរៀបចំ អនុវត្តផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្ត គ.ភ.ឃ.ស.។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- អភិវឌ្ឍសមត្ថភាពលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការរៀបចំ អនុវត្តផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្ត គ.ភ.ឃ.ស. ការតាមដានត្រួតពិនិត្យ ការរៀបចំរបាយការណ៍ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា
- តាមដាន គាំទ្រលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអភិវឌ្ឍសមត្ថភាព និងគាំទ្ររដ្ឋបាលឃុំ សង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាល និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្ត គ.ភ.ឃ.ស.
- តាមដាន គាំទ្រលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។

**តារាងទី៥ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៥.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំដល់គណៈបញ្ជាការឯកភាពរដ្ឋបាល | ៣ | ៣ | ៣ | ៣ | ៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | ភាគរយលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តដែលបានចុះគាំទ្រ | ៥០% | ៧០% | ៧០% | ៧០% | ៧០% |
| ៣ | ភាគរយលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ខេត្តដែលបានគាំទ្រ | ២០% | ៣០% | ៥០% | ៥០% | ៥០% |
| ៤ | ភាគរយរដ្ឋបាលឃុំ សង្កាត់ដែលបានចុះគាំទ្រ | ២០% | ៣០% | ៥០% | ៥០% | ៥០% |

### លទ្ធផលរំពឹងទុក ១.១.៦ ៖ ការបំពេញតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធនឹងការអនុវត្ត គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានពង្រឹង

ក្រុមប្រឹក្សាឃុំ សង្កាត់រួមទាំងប៉ុស្តិ៍នគរបាលរដ្ឋបាល គឺប្រតិបត្តិករដ៏សំខាន់ក្នុងការអនុវត្តគោល-នយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ជាពិសេសការផ្តល់សេវារដ្ឋបាល ការអភិវឌ្ឍ មូលដ្ឋាន ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការលើកកម្ពស់អនាម័យ សោភ័ណ្ឌភាព និងបរិស្ថានល្អក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- តាមដាន ត្រួតពិនិត្យ គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍសមត្ថភាព និងគាំទ្ររដ្ឋបាលឃុំ សង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាល និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្ត គ.ភ.ឃ.ស.
- តាមដាន ត្រួតពិនិត្យ គាំទ្ររដ្ឋបាលឃុំ សង្កាត់ក្នុងការរៀបចំ អនុវត្តផែនការ និងគម្រោងសកម្មភាពពាក់ព័ន្ធនឹងគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- សិក្សារៀបចំ និងពង្រឹងយន្តការនានានៅថ្នាក់ឃុំ សង្កាត់ក្នុងការទទួលខុសត្រូវ សម្របសម្រួលការអនុវត្ត គ.ភ.ឃ.ស.

**តារាងទី៦ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៦.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ភាគរយឃុំ សង្កាត់ដែលបានគាំទ្រក្នុងការអនុវត្ត គ.ភ.ឃ.ស. | ២០% | ៣០% | ៥០% | ៥០% | ៥០% |
| ២ | ការសិក្សា និងរៀបចំយន្តការ គ.ភ.ឃ.ស. នៅថ្នាក់ឃុំ សង្កាត់ | | ១ | | | |

### លទ្ធផលរំពឹងទុក ១.១.៧ ៖ កិច្ចសហការរវាងគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ជាមួយកម្មវិធីកំណែទម្រង់នានា ត្រូវបានលើកកម្ពស់

ការអនុវត្ត គ.ភ.ឃ.ស. មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយកម្មវិធីកំណែទម្រង់នានាដូចជា កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ និងកម្មវិធីកំណែទម្រង់វិស័យនានា។ អាស្រ័យហេតុនេះ ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ សកម្មភាព ជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំ និងបង្ហាញសេចក្តីសង្ខេបអំពីគោលនយោបាយ ដើម្បីបង្ហាញក្នុងកិច្ចប្រជុំ របស់លេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់៣បូក១ និងកម្មវិធីកំណែទម្រង់វិស័យនានា
- ចូលរួមក្នុងកិច្ចប្រជុំរបស់លេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់៣បូក១ និងកម្មវិធីកំណែទម្រង់វិស័យនានា
- ចូលរួមជាមួយលេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់៣បូក១ និងកម្មវិធីកំណែទម្រង់វិស័យនានាក្នុងការត្រួតពិនិត្យ និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការ អនុវត្តកម្មវិធីកំណែទម្រង់នានា
- សហការរៀបចំលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការលើកកម្ពស់ការរៀបចំ វិភាជ និងប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រគម្រោងសកម្មភាពនានានៃ គ.ភ.ឃ.ស.។

**តារាងទី៧ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.១.៧.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំសេចក្តីសង្ខេបអំពី គ.ភ.ឃ.ស. | ១ | | | | |
| ២ | ការចូលរួមកិច្ចប្រជុំកំណែទម្រង់៣បូក១ | ៤ | ៤ | ៤ | ៤ | ៤ |
| ៣ | ចំនួនលិខិតបទដ្ឋានដែលបានរៀបចំ | ២ | ២ | ២ | ២ | ២ |

## យុទ្ធសាស្ត្រទី ១.២ ៖ រៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងឯកសារបច្ចេកទេសនានា ពាក់ព័ន្ធនឹងការអនុវត្ត គ.ភ.ឃ.ស.

### លទ្ធផលរំពឹងទុក ១.២.១ ៖ លិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងឯកសារបច្ចេកទេសចាំបាច់នានាពាក់ព័ន្ធនឹង គ.ភ.ឃ.ស. ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត

ដើម្បីអនុវត្ត គ.ភ.ឃ.ស. ទាមទារការរៀបចំ ដាក់ចេញលិខិតបទដ្ឋាន សេចក្តីណែនាំ និងឯកសារបច្ចេកទេសចាំបាច់នានា។ កន្លងមក ក្រសួងមហាផ្ទៃបានរៀបចំ ដាក់ឱ្យអនុវត្តនូវ លិខិតបទដ្ឋាន និងឯកសារមួយចំនួនសម្រាប់អនុវត្ត គ.ភ.ឃ.ស. ដូចជា លិខិតជូនដំណឹងស្តីពី ការអនុវត្តចលនាប្រឡងប្រណាំងគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃលេខាធិការដ្ឋានសម្រាប់គាំទ្រការអនុវត្ត គ.ភ.ឃ.ស. និង សៀវភៅណែនាំស្តីពីការអនុវត្ត គ.ភ.ឃ.ស.។ ដូច្នេះ នៅមានលិខិតបទដ្ឋាន សេចក្តីណែនាំ និងឯកសារបច្ចេកទេសជាច្រើនទៀត ដែលត្រូវបន្តរៀបចំ និងដាក់ចេញដើម្បីអនុវត្ត គ.ភ.ឃ.ស.។ អាស្រ័យហេតុនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុក នេះរួមមាន ៖

- សិក្សា រៀបចំបញ្ជីលិខិតបទដ្ឋាន សេចក្តីណែនាំដែលត្រូវរៀបចំ និងដាក់ឱ្យអនុវត្តក្នុង រយៈពេលពីឆ្នាំ២០២៤-២០២៨ រួមបញ្ចូលទាំងលិខិតបទដ្ឋាន សេចក្តីណែនាំនានាដែលត្រូវពិនិត្យ និងកែសម្រួល
- រៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋាន សេចក្តីណែនាំនានាដែលបានកំណត់ ដោយសហការ និងប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធនានា។

**តារាងទី៨ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.២.១.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំបញ្ជីលិខិតបទដ្ឋាន | ១ | ១ | ១ | ១ | ១ |
| ២ | ចំនួនលិខិតបទដ្ឋានដែលបានរៀបចំ | ៣ | ៣ | ៣ | ៣ | ៣ |

លទ្ធផលរំពឹងទុក ១.២.២ ៖ លិខិតបទដ្ឋានគតិយុត្ត សេចក្ដីណែនាំ និងឯកសារបច្ចេកទេសដែលបានដាក់ចេញ ត្រូវបានផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពដល់ភាគីពាក់ព័ន្ធនានា

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- សិក្សាវាយតម្លៃ និងកំណត់លិខិតបទដ្ឋាន សេចក្ដីណែនាំនានាដែលត្រូវធ្វើការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល និងបញ្ចូលក្នុងផែនការអភិវឌ្ឍសមត្ថភាព ប្រចាំឆ្នាំរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស.
- រៀបចំវិធីសាស្ត្រ ឯកសារ សម្ភារ សម្រាប់ការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល
- អនុវត្តការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលអំពីលិខិតបទដ្ឋាន សេចក្ដីណែនាំនានា ដោយសហការជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា។

**តារាងទី៩ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.២.២.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | បញ្ជីលិខិតបទដ្ឋានដែលបានរៀបចំសម្រាប់ការផ្សព្វផ្សាយ | ១ | ១ | ១ | ១ | ១ |
| ២ | វិធីសាស្ត្រ ឯកសារ និងសម្ភារបានរៀបចំ | ១ | ១ | ១ | ១ | ១ |
| ៣ | ចំនួនការផ្សព្វផ្សាយ និងវគ្គបណ្ដុះបណ្ដាល | ៣ | ៣ | ៣ | ៣ | ៣ |

## យុទ្ធសាស្ត្រទី ១.៣ ៖ លើកកម្ពស់ចំណេះដឹង និងសមត្ថភាពអំពី គ.ភ.ឃ.ស.

លទ្ធផលរំពឹងទុក ១.៣.១ ៖ សមត្ថភាពរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្នុងការសម្របសម្រួល ត្រួតពិនិត្យ និងគាំទ្រការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានអភិវឌ្ឍ

លេខាធិការដ្ឋាន គ.ភ.ឃ.ស. ទើបត្រូវបានបង្កើតឡើងក្នុងខែកក្កដា ឆ្នាំ២០២២ ដែលមានតួនាទីជាសេនាធិការឱ្យក្រសួងមហាផ្ទៃក្នុងការសម្របសម្រួល ការតាមដានត្រួតពិនិត្យ និងផ្ដល់ការគាំទ្រជាប្រចាំដល់ការអនុវត្ត គ.ភ.ឃ.ស.។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ភ.ឃ.ស. ត្រូវមានធនធានមនុស្ស និងសមត្ថភាពសមស្រប ដើម្បីអនុវត្តភារកិច្ចនេះប្រកបដោយប្រសិទ្ធភាព។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- សិក្សា និងវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់ថ្នាក់ដឹកនាំ និងបុគ្គលិក លេខាធិការដ្ឋាន គ.ភ.ឃ.ស.

- រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់លេខាធិការដ្ឋាន ដោយសហការជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា
- រៀបចំទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស ដើម្បីសិក្សារៀនសូត្រ និងដកស្រង់ បទពិសោធន៍ដែលពាក់ព័ន្ធនឹង គ.ភ.ឃ.ស.
- រៀបចំផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀតពាក់ព័ន្ធនឹង គ.ភ.ឃ.ស. និងគោលនយោបាយ លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត។

**តារាងទី១០ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.៣.១.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ | ១ | ១ | ១ | ១ | ១ |
| ២ | ចំនួនទស្សនកិច្ចសិក្សាដែលបានរៀបចំ | | ១ | | ១ | |
| ៣ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាព | | ១ | | | |

លទ្ធផលរំពឹងទុក ១.៣.២ ៖ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានាមានចំណេះដឹង និងសមត្ថភាពច្បាស់លាស់អំពី គ.ភ.ឃ.ស.

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវចូលរួមអនុវត្តដោយប្រជាពលរដ្ឋ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគី ពាក់ព័ន្ធនានា ស្របតាមជំនាញ តួនាទី និងភារកិច្ចរបស់ខ្លួន។ អាស្រ័យហេតុនេះ ស្ថាប័នទាំងនេះត្រូវមានសមត្ថភាពសមស្រប ដើម្បីអនុវត្តគោលនយោបាយនេះប្រកបដោយប្រសិទ្ធភាព។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖
- សិក្សាវាយតម្លៃអំពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នអនុវត្ត ៖
  - ក្រុមការងាររបស់ក្រសួង ស្ថាប័ន
  - រដ្ឋបាលថ្នាក់ក្រោមជាតិ
  - គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលេខាធិការដ្ឋានរបស់ខ្លួន
  - ក្រុមប្រឹក្សាឃុំ សង្កាត់ និងប៉ុស្តិ៍នគរបាលរដ្ឋបាល
  - កងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ
  - អង្គការសង្គមស៊ីវិល
  - ភាគីពាក់ព័ន្ធផ្សេងទៀត។
- រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- រៀបចំទស្សនកិច្ចសិក្សា ដើម្បីសិក្សារៀនសូត្រ និងដកស្រង់បទពិសោធន៍ដែលពាក់ព័ន្ធនឹង គ.ភ.ឃ.ស.។

**តារាងទី១១ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.៣.២.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | ១ | ១ | ១ | ១ | ១ |
| ២ | ផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ | ១ | ១ | ១ | ១ | ១ |
| ៣ | ចំនួនទស្សនកិច្ចសិក្សាដែលបានរៀបចំ | ១ | | ១ | | ១ |

លទ្ធផលរំពឹងទុក ១.៣.៣ ៖ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាមានការយល់ដឹង ច្បាស់លាស់អំពី គ.ភ.ឃ.ស.

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវចូលរួមអនុវត្តដោយប្រជាពលរដ្ឋ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគី ពាក់ព័ន្ធនានា ស្របតាមជំនាញ តួនាទី និងភារកិច្ចរបស់ខ្លួន។ អាស្រ័យហេតុនេះ ស្ថាប័នទាំងនេះត្រូវមានសមត្ថភាព សមស្រប ដើម្បីអនុវត្តគោលនយោបាយនេះប្រកបដោយប្រសិទ្ធភាព។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំការអប់រំ និងផ្សព្វផ្សាយអំពី គ.ភ.ឃ.ស. តាមគ្រប់រូបភាព និងតាមរយៈមធ្យោបាយផ្សេងៗ
- លើកកម្ពស់រៀបចំវេទិកាសាធារណៈ ដើម្បីដោះស្រាយសំណើ និងសំណូមពរនានារបស់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹង គ.ភ.ឃ.ស.។

**តារាងទី១២ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ១.៣.៣.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ចំនួនការផ្សព្វផ្សាយប្រចាំឆ្នាំស្ដីពី គ.ភ.ឃ.ស. | ២ | ៣ | ៣ | ៣ | ៣ |
| ២ | ចំនួនវេទិកាសាធារណៈដែលបានរៀបចំ | ៤ | ៤ | ៤ | ៤ | ៤ |
| ៣ | ភាគរយនៃសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋដែលបានដោះស្រាយ | ៧០% | ៧០% | ៧០% | ៧០% | ៧០% |

**គោលដៅទី២ ៖**

**លើកកម្ពស់ការអនុវត្ត គ.ភ.ឃ.ស. ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព សមភាពយេនឌ័រ បរិយាប័ន្ន សមធម៌សង្គម និងក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។**

**យុទ្ធសាស្ត្រទី ២.១ ៖ គោលនយោបាយ គ.ភ.ឃ.ស. ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព**

លទ្ធផលរំពឹងទុក ២.១.១ ៖ លក្ខណសម្បត្តិទាំង ៧ នៃ គ.ភ.ឃ.ស. ត្រូវបានរៀបចំ និងបញ្ចូលក្នុងផែនការ និងថវិការបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវចូលរួមអនុវត្តដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។ អាស្រ័យហេតុនេះ ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ ក្រោមជាតិត្រូវរៀបចំ និងបញ្ចូលសកម្មភាព និងថវិកានៃ គ.ភ.ឃ.ស. ទៅក្នុងផែនការ និងគម្រោង ថវិការបស់ខ្លួន ដើម្បីធានាថា សកម្មភាពអនុវត្ត គ.ភ.ឃ.ស. ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមានថវិកាគ្រប់គ្រាន់ និងត្រូវបានអនុវត្តប្រកប ដោយប្រសិទ្ធភាព និងតម្លាភាព។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំវិធីសាស្ត្រ និងឧបករណ៍នានាសម្រាប់ការវិភាគ និងកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយនានាពាក់ព័ន្ធនឹង គ.ភ.ឃ.ស. ដើម្បីបញ្ចូលក្នុងផែនការ និង គម្រោងថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំ និងណែនាំក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរៀបចំ និងដាក់បញ្ចូលសកម្មភាព និងថវិកាសម្រាប់អនុវត្ត គ.ភ.ឃ.ស. ក្នុងផែនការ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន
- តាមដាន និងគាំទ្រក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងដាក់បញ្ចូលសកម្មភាព និងថវិកាសម្រាប់អនុវត្ត គ.ភ.ឃ.ស. ក្នុងផែនការ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

**តារាងទី១៣ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.១.១.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំវិធីសាស្ត្រ និងឧបករណ៍នានា សម្រាប់បញ្ចូល គ.ភ.ឃ.ស. ក្នុងផែនការ | ១ | | | | |
| ២ | ភាគរយក្រសួង ស្ថាប័នដែលបានបញ្ចូលសកម្មភាពនៃ គ.ភ.ឃ.ស. ក្នុងផែនការរបស់ខ្លួន | ៥០% | ៧០% | ៩០% | ១០០% | ១០០% |
| ៣ | ភាគរយរាជធានី ខេត្តដែលបានបញ្ចូលសកម្មភាពនៃ គ.ភ.ឃ.ស. ក្នុងផែនការរបស់ខ្លួន | ៥០% | ៧០% | ៩០% | ១០០% | ១០០% |
| ៤ | ភាគរយក្រុង ស្រុក ខណ្ឌដែលបានបញ្ចូលសកម្មភាពនៃ គ.ភ.ឃ.ស. ក្នុងផែនការរបស់ខ្លួន | ៥០% | ៧០% | ៩០% | ១០០% | ១០០% |
| ៥ | ភាគរយឃុំ សង្កាត់ដែលបានបញ្ចូលសកម្មភាពនៃ គ.ភ.ឃ.ស. ក្នុងផែនការរបស់ខ្លួន | ១០០% | ១០០% | ១០០% | ១០០% | ១០០% |

### លទ្ធផលរំពឹងទុក ២.១.២ ៖ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស.របស់ស្ថាប័នទទួលខុសត្រូវ ត្រូវបានរៀបចំ និងអនុវត្តប្រកបដោយប្រសិទ្ធភាព

ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្ត គ.ភ.ឃ.ស. ត្រូវធ្វើឡើងតាមរយៈផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលត្រូវរៀបចំដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមសៀវភៅណែនាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. និងនីតិវិធីពាក់ព័ន្ធនានា។ អាស្រ័យហេតុនេះ សកម្មភាពសំខាន់ៗដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះរួមមាន ៖

- ផ្តល់ការណែនាំដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស.

- តាមដាន និងគាំទ្រក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. ដោយមានការចូលរួម និងប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធនានា។

**តារាងទី១៤ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.១.២.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំ និងចេញការណែនាំអំពីការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | ១ | ១ | ១ | ១ | ១ |
| ២ | ភាគរយក្រសួង ស្ថាប័ន ដែលបានរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | ៥០% | ៧០% | ៩០% | ១០០% | ១០០% |
| ៣ | ភាគរយរាជធានី ខេត្តដែលបានរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | ៥០% | ១០០% | ១០០% | ១០០% | ១០០% |
| ៤ | ភាគរយក្រុង ស្រុក ខណ្ឌ ដែលបានរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | ៥០% | ៧០% | ១០០% | ១០០% | ១០០% |
| ៥ | ភាគរយឃុំ សង្កាត់ ដែលបានរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | ៥០% | ៧០% | ១០០% | ១០០% | ១០០% |

លទ្ធផលរំពឹងទុក ២.១.៣ ៖ ការត្រួតពិនិត្យ និងគាំទ្រការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់ស្ថាប័នអនុវត្ត

ការអនុវត្តផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្ត គ.ភ.ឃ.ស. ទាមទារការតាមដានត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថា សកម្មភាពនានាត្រូវបានអនុវត្ត តាមពេលវេលាកំណត់ និងប្រកបដោយប្រសិទ្ធភាព។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- ត្រួតពិនិត្យ និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្ត គ.ភ.ឃ.ស.
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស.
- រៀបចំរបាយការណ៍ស្តីពីការអនុវត្ត គ.ភ.ឃ.ស. ជូនក្រសួងមហាផ្ទៃ។

**តារាងទី១៥ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.១.៣.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ភាគរយក្រសួង ស្ថាប័នដែលបានគាំទ្រក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្ត គ.ភ.យ.ស. | ៦០% | ៧០% | ៧០% | ៧០% | ៧០% |
| ២ | ភាគរយរាជធានី ខេត្តដែលបានគាំទ្រក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្ត គ.ភ.យ.ស. | ៥០% | ៥០% | ៥០% | ៥០% | ៥០% |
| ៣ | កិច្ចប្រជុំប្រចាំត្រីមាសដែលបានរៀបចំ | ៤ | ៤ | ៤ | ៤ | ៤ |
| ៤ | ការរៀបចំរបាយការណ៍ដែលបានរៀបចំ | ២ | ២ | ២ | ២ | ២ |

លទ្ធផលរំពឹងទុក ២.១.៤ ៖ ការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្ត គ.ភ.យ.ស. និង គ.ភ.យ.ស. របស់រាជរដ្ឋាភិបាល

ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្ត គ.ភ.យ.ស. របស់លេខាធិការដ្ឋាន គ.ភ.យ.ស. ក៏ដូចជាការអនុវត្ត គ.ភ.យ.ស. របស់រាជរដ្ឋាភិបាល ទាមទារការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងគោលនយោបាយនេះ។ វិធីសាស្ត្រសំខាន់ៗ សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រមានរៀបរាប់បន្ថែមក្នុងផ្នែកទី៦ នៃឯកសារនេះ។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- សម្របសម្រួល និងរៀបចំទិន្នន័យដើមគ្រានៃការអនុវត្តផែនការយុទ្ធសាស្ត្រ
- សម្របសម្រួល និងការអនុវត្តផែនការយុទ្ធសាស្ត្រ ៖
  - ការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ
  - ការវាយតម្លៃពាក់កណ្តាល និង
  - ការវាយតម្លៃចុងបញ្ចប់នៃផែនការយុទ្ធសាស្ត្រ
- សម្របសម្រួល និងអនុវត្តការវាយតម្លៃ គ.ភ.យ.ស. របស់រាជរដ្ឋាភិបាល។

**តារាងទី១៦ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.១.៤.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | ការរៀបចំទិន្នន័យដើមគ្រា | ១ | | | | |
| ២ | ការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ | ១ | ១ | ១ | ១ | ១ |
| ៣ | ការវាយតម្លៃពាក់កណ្តាលផែនការ | | | ១ | | |
| ៤ | ការវាយតម្លៃចុងបញ្ចប់ផែនការ | | | | | ១ |
| ៥ | ការវាយតម្លៃការអនុវត្ត គ.ភ.យ.ស. | | | | ១ | |

## យុទ្ធសាស្ត្រទី ២.២ ៖ លើកកម្ពស់ភាពជាដៃគូក្នុងការអនុវត្ត គ.ភ.ឃ.ស.

### លទ្ធផលរំពឹងទុក ២.២.១ ៖ យុទ្ធសាស្ត្រស្ដីពីភាពជាដៃគូសម្រាប់អនុវត្ត គ.ភ.ឃ.ស. ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាល ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងវិស័យសាធារណៈ វិស័យឯកជន ភាគីពាក់ព័ន្ធនានា និងប្រជាពលរដ្ឋ ដើម្បីជ្រួតជ្រាប និងចូលរួមអនុវត្តប្រកបដោយជោគជ័យ។ ក្នុងន័យនេះ គ.ភ.ឃ.ស. ត្រូវចូលរួមអនុវត្ត ដោយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពសំខាន់ៗដែលត្រូវអនុវត្តរួមមានដូចខាងក្រោម ៖

- សិក្សា និងរៀបចំយុទ្ធសាស្ត្រស្ដីពីការលើកកម្ពស់ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានាក្នុងការអនុវត្ត គ.ភ.ឃ.ស.
- អនុម័ត និងផ្សព្វផ្សាយយុទ្ធសាស្ត្រស្ដីពីភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានាក្នុងការអនុវត្ត គ.ភ.ឃ.ស.
- សម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិលនានា ក្នុងការរៀបចំ អនុវត្តគម្រោង និងកម្មវិធីនានាស្ដីពីការអនុវត្ត គ.ភ.ឃ.ស.។

**តារាងទី១៧ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.២.១.**

| ល.រ. | សូចនាករ | ដើមគ្រា | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|
| ១ | ការសិក្សា និងរៀបចំយុទ្ធសាស្ត្រស្ដីពីភាពជាដៃគូ | | ១ | | | | |
| ២ | ការអនុម័ត និងផ្សព្វផ្សាយយុទ្ធសាស្ត្រស្ដីពីភាពជាដៃគូ | | | ១ | | | |
| ៣ | គម្រោង កម្មវិធីនានាដែលគាំទ្រដោយដៃគូស្ដីពីការអនុវត្ត គ.ភ.ឃ.ស. | | | | ១ | ១ | ១ |

### លទ្ធផលរំពឹងទុក ២.២.២ ៖ យន្តការភាពជាដៃគូសម្រាប់អនុវត្ត គ.ភ.ឃ.ស. ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ ដើម្បីសម្របសម្រួលជាមួយដៃគូនានា

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាល ត្រូវចូលរួមអនុវត្ត ដោយប្រជាពលរដ្ឋ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យ ឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំលក្ខខណ្ឌការងាររបស់គណៈកម្មការ ឬក្រុមការងារបច្ចេកទេសសម្រាប់ការអនុវត្ត គ.ភ.ឃ.ស. ដោយមានសមាសភាពចូលរួមពីតំណាងដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលនានា។ ធាតុសំខាន់ៗនៃលក្ខខណ្ឌការងារមានដូចជា ៖

- ○ សមាសភាព
- ○ តួនាទី ភារកិច្ច
- ○ របៀបរបបបំពេញការងារ។ល។

- បង្កើតគណៈកម្មការ ឬក្រុមការងារបច្ចេកទេសសម្រាប់ការអនុវត្ត គ.ភ.ឃ.ស.
- រៀបចំកិច្ចប្រជុំគណៈកម្មការ ឬក្រុមការងារបច្ចេកទេសការអនុវត្ត គ.ភ.ឃ.ស. ជាប្រចាំ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត គ.ភ.ឃ.ស.
- ចុះតាមដាន និងត្រួតពិនិត្យការអនុវត្ត គ.ឃ.ភ.ស. នៅតាមមូលដ្ឋាន។

**តារាងទី១៤ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.២.២.**

| ល.រ. | សូចនាករ | ដើមគ្រា | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|
| ១ | ការបង្កើតក្រុមការងារ | | ១ | | | | |
| ២ | ការរៀបចំកិច្ចប្រជុំក្រុមការងារ | | ១ | ២ | ២ | ២ | ២ |

## យុទ្ធសាស្ត្រទី ២.៣ ៖ ជំរុញចលនាប្រឡងប្រណាំងស្តីពីការអនុវត្ត គ.ភ.ឃ.ស.

លទ្ធផលរំពឹងទុក ២.៣.១ ៖ ចលនាប្រឡងប្រណាំងការអនុវត្ត គ.ភ.ឃ.ស. តាមវិស័យជំនាញនីមួយៗ ត្រូវបានពិនិត្យ កែសម្រួល និងលើកកម្ពស់

ចលនាប្រឡងប្រណាំងស្តីពីការអនុវត្ត គ.ភ.ឃ.ស. បានចាប់ផ្តើមអនុវត្តតាំងឆ្នាំ២០១១ ដែលសម្របសម្រួលដោយក្រសួងមហាផ្ទៃក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» ដោយផ្តោតជាសំខាន់លើបទល្មើស សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ជាមួយគ្នានេះដែរ ក្រសួងសុខាភិបាល និងក្រសួងបរិស្ថានក៏បានរៀបចំ និងសម្របសម្រួលចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» លើប្រធានបទពាក់ព័ន្ធនឹងវិស័យរបស់ខ្លួន។

បន្ទាប់ពី គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» របស់រាជរដ្ឋាភិបាលត្រូវបាន ដាក់ចេញក្នុងឆ្នាំ២០២១ ផ្អែកលើសំណើរបស់ក្រសួងមហាផ្ទៃ រាជរដ្ឋាភិបាលក៏បានណែនាំ និងប្រគល់ភារកិច្ចឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនដូចជា ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងយុត្តិធម៌ និងក្រសួង ស្ថាប័ន ផ្សេងទៀតដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈក្នុងការរៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ យន្តការ និងលក្ខណៈវិនិច្ឆ័យនានាសម្រាប់ចលនាប្រឡងប្រណាំងអនុវត្តលក្ខណសម្បត្តិនៃ គ.ភ.ឃ.ស. ស្របតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

ជារួម ចលនាប្រឡងប្រណាំងដែលបានអនុវត្តកន្លងមក បានរៀបចំយន្តការ ដំណើរការ នីតិវិធី លក្ខណៈវិនិច្ឆ័យ និងសូចនាករផ្សេងៗគ្នា។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវមានការពិនិត្យ និងកែសម្រួលឱ្យបានសមស្រប ដើម្បីជានាប្រសិទ្ធភាពនៃការអនុវត្តចលនាប្រឡងប្រណាំង។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពសំខាន់ៗដែលត្រូវអនុវត្តរួមមានដូចខាងក្រោម ៖

- ពិនិត្យមើលឡើងវិញអំពីចលនាប្រឡងប្រណាំងនានា ដែលបានអនុវត្តកន្លងមក ដោយផ្តោត

លើយន្តការ ដំណើរការ នីតិវិធី លក្ខណៈវិនិច្ឆ័យ និងសូចនាករដែល បានរៀបចំ និងប្រើប្រាស់
- រៀបចំ និងដាក់ចេញសេចក្តីណែនាំរួមរបស់ក្រសួងមហាផ្ទៃ និងជាសេនាធិការជូនរាជរដ្ឋាភិបាល ស្តីពីចលនាប្រឡងប្រណាំងអនុវត្ត គ.ភ.ឃ.ស.
- តាមដាន ត្រួតពិនិត្យ និងគាំទ្រក្រសួង ស្ថាប័នក្នុងការរៀបចំចលនាប្រឡងប្រណាំងអនុវត្ត គ.ភ.ឃ.ស.។

**តារាងទី១៩ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.៣.១.**

| ល.រ. | សូចនាករ | ដើមគ្រា | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|
| ១ | ការពិនិត្យមើលឡើងវិញអំពីចលនាប្រឡងប្រណាំងដែលបានអនុវត្ត | | ១ | | | | |
| ២ | ការដាក់ចេញសេចក្តីណែនាំរួមអំពីចលនាប្រឡងប្រណាំងដែលបានអនុវត្ត | | ១ | | | | |
| ៣ | ចលនាប្រឡងប្រណាំងដែលបានអនុវត្តស្របតាមសេចក្តីណែនាំដែលបានកែសម្រួល | | | ២ | ៣ | ៥ | ៥ |

លទ្ធផលរំពឹងទុក ២.៣.២ ៖ គោលនយោបាយលើកទឹកចិត្តស្តីពីការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានរៀបចំ

ការលើកទឹកចិត្តក្នុងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកត្តាមួយដ៏មាន សារសំខាន់ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

កន្លងមក ចលនាប្រឡងប្រណាំងការអនុវត្ត គ.ភ.ឃ.ស. ក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ពាក់ព័ន្ធនឹងបទល្មើស សណ្តាប់ធ្នាប់សាធារណៈ អំពើអនាចារ ការជួញដូរមនុស្ស (លក្ខណៈសម្បត្តិទី២ ទី៣ និងទី៤) ក្រសួងបានផ្តល់ការលើកទឹកចិត្តជាថវិកាដល់រដ្ឋបាលឃុំ សង្កាត់ដែល ទទួលបានជ័យលាភីលេខ១ និងលេខ២ ហើយថវិកាលើកទឹកចិត្តនេះត្រូវបានបែងចែកសម្រាប់រដ្ឋបាលឃុំ សង្កាត់ និងសម្រាប់ប៉ុស្តិ៍នគរបាលរដ្ឋបាល។ ជាមួយគ្នានេះដែរ ក្រសួងបរិស្ថានក៏មានការលើកទឹកចិត្តដល់រដ្ឋបាលឃុំ សង្កាត់ដែលទទួលបានស្នាដៃល្អក្នុងការលើកកម្ពស់អនាម័យ សោភណភាព និងបរិស្ថាន (លក្ខណៈសម្បត្តិទី៥) ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងគោលបំណងផ្តល់ការលើកទឹកចិត្តដែលមានលក្ខណៈជាប្រព័ន្ធ និងមាននិរន្តរភាពក្នុង ចលនាប្រឡងប្រណាំងអនុវត្ត គ.ភ.ឃ.ស. រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាស្ថាប័ន និងបុគ្គល) ចាំបាច់ត្រូវមានលិខិតបទដ្ឋាន និងសេចក្តីណែនាំសម្រាប់អនុវត្ត ប្រកបដោយតម្លាភាព និងគ្មានភាពលម្អៀង។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖
- ពិនិត្យមើលឡើងវិញនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាដែលបានដាក់ឱ្យ អនុវត្តពាក់ព័ន្ធនឹងចលនាប្រឡងប្រណាំងអនុវត្ត គ.ភ.ឃ.ស.
- សិក្សាមេរៀន និងបទពិសោធន៍ពីបណ្តាប្រទេសនានាក្នុងតំបន់អំពីការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានស្នាដៃល្អក្នុងការបំពេញការងារ

- រៀបចំទស្សនកិច្ចសិក្សានៅបណ្តាប្រទេសក្នុងតំបន់ ដើម្បីដកស្រង់បទពិសោធន៍អំពីការផ្តល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានស្នាដៃល្អក្នុងការបំពេញការងារ
- រៀបចំគោលនយោបាយ និងលិខិតបទដ្ឋាននានាសម្រាប់ការលើក ទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិលក្ខណៈជាស្ថាប័ន និងដល់មន្ត្រីដែលមានស្នាដៃល្អក្នុងការអនុវត្ត គ.ភ.ឃ.ស.។

**តារាងទី២០ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.៣.២.**

| ល.រ. | សូចនាករ | ដើមគ្រា | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|
| ១ | ការពិនិត្យមើលឡើងវិញ | | | | ១ | | |
| ២ | ទស្សនកិច្ចសិក្សាក្នុងតំបន់ | | | | | ១ | |
| ៣ | គោលនយោបាយលើកទឹកចិត្ត | | | | | | ១ |

## យុទ្ធសាស្ត្រទី ២.៤ ៖ ពង្រឹងប្រព័ន្ធទិន្នន័យសម្រាប់អនុវត្ត និងគ្រប់គ្រង គ.ភ.ឃ.ស. តាមរយៈប្រព័ន្ធឌីជីថល

### លទ្ធផលរំពឹងទុក ២.៤.១ ៖ ការអនុវត្តលក្ខណសម្បត្តិនានានៃ គ.ភ.ឃ.ស. ត្រូវបានពង្រឹង តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

បច្ចុប្បន្ន ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងត្រូវបាន ប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការងារគ្រប់គ្រង ការងាររដ្ឋបាល ការងារហិរញ្ញវត្ថុ ការផ្តល់សេវា រដ្ឋបាលសាធារណៈ ការរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ការចែករំលែកព័ត៌មាន និងការប្រាស្រ័យទាក់ទង។ល។ ទោះជាយ៉ាងនេះក្តី កិច្ចការភាគច្រើនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កំពុងត្រូវបានអនុវត្តដោយផ្អែកលើការបំពេញបែបបទដោយដៃលើក្រដាសស្នាមនៅឡើយ ជាហេតុ ធ្វើឱ្យការបំពេញការងារ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ និងការប្រាស្រ័យទាក់ទងជាមួយសាធារណជន មានភាពយឺតយ៉ាវ និងមានការលំបាក។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវពង្រឹងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំ និងគាំទ្រឧបករណ៍ សម្ភារព័ត៌មានវិទ្យាដល់ថ្នាក់ដឹកនាំ និងបុគ្គលិក លេខាធិការដ្ឋាន គ.ភ.ឃ.ស.
- បង្កើត និងគាំទ្រប្រព័ន្ធអ៊ិនធឺណែតរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស.
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណែតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- លើកកម្ពស់ការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋ តាមរយៈ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- លើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- លើកកម្ពស់ការគ្រប់គ្រងទិន្នន័យបទល្មើស ទិន្នន័យការរៀបចំវេទិកាសាធារណៈ ការផ្សព្វផ្សាយគោលនយោបាយ និងការចងក្រងប្រជាការពារ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**តារាងទី២១ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.៤.១.**

| ល.រ. | សូចនាករ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ១ | គាំទ្រឧបករណ៍ និងសម្ភារៈព័ត៌មានវិទ្យាដល់ថ្នាក់ដឹកនាំ និងបុគ្គលិកលេខាធិការដ្ឋាន គ.ភ.ឃ.ស. | ១ | | | | |
| ២ | បង្កើត និងគាំទ្រប្រព័ន្ធអ៊ិនធឺណែត | ១ | | | | |
| ៣ | ភាគរយក្រុង ស្រុក ខណ្ឌមានប្រព័ន្ធអ៊ិនធឺណែត | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ៤ | ភាគរយឃុំ សង្កាត់មានប្រព័ន្ធអ៊ិនធឺណែត | | | | | |
| ៥ | ចំនួនវិស័យដែលផ្តល់សេវាតាមប្រព័ន្ធអនឡាញ | ៥ | ៦ | ៧ | ១០ | ១៥ |
| ៦ | ចំនួនប្រព័ន្ធទិន្នន័យផ្តល់សេវាដែលបានបង្កើត | | | | | |

លទ្ធផលរំពឹងទុក ២.៤.២ ៖ ប្រព័ន្ធទិន្នន័យថ្នាក់ជាតិសម្រាប់ការគ្រប់គ្រង គ.ភ.ឃ.ស. ត្រូវបានរៀបចំ

ក្នុងការគ្រប់គ្រង និងអនុវត្ត គ.ភ.ឃ.ស. វិស័យមួយចំនួនបានរៀបចំ និងដាក់ឱ្យដំណើរការ ប្រព័ន្ធទិន្នន័យមូលដ្ឋាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពនៃការបំពេញការងាររបស់ខ្លួន ដូចជា ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងបទល្មើស ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការទប់ស្កាត់អំពើអនាចារ ការជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ ការគ្រប់គ្រង គ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនានា។ ដើម្បីជួយក្រសួងមហាផ្ទៃក្នុងការទទួលបានជាប្រចាំ និងទាន់ពេលវេលានូវព័ត៌មាន និងទិន្នន័យនានាស្តីពីការអនុវត្ត គ.ភ.ឃ.ស. ដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា ចាំបាច់ត្រូវមានប្រព័ន្ធទិន្នន័យមូលដ្ឋានរួមមួយ ដែលបញ្ចូលនូវទិន្នន័យសំខាន់ៗ និងចាំបាច់របស់វិស័យនានាពាក់ព័ន្ធនឹង គ.ភ.ឃ.ស. សម្រាប់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងចាត់វិធានការនានាបានសមស្រប និងទាន់ពេលវេលា។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តរួមមាន ៖

- សិក្សាប្រព័ន្ធទិន្នន័យមូលដ្ឋាននានា ដែលបានដាក់ឱ្យអនុវត្ត និងកំពុងប្រើប្រាស់ ដោយវិស័យនានាពាក់ព័ន្ធនឹង គ.ភ.ឃ.ស. និងកំណត់ជម្រើសនានាសម្រាប់បង្កើតប្រព័ន្ធទិន្នន័យមូលដ្ឋានថ្នាក់ជាតិនៃ គ.ភ.ឃ.ស.
- ពិនិត្យ និងឯកភាពលើជម្រើសសមស្របសម្រាប់បង្កើតប្រព័ន្ធទិន្នន័យមូលដ្ឋានថ្នាក់ជាតិដែលរួមបញ្ចូលទិន្នន័យសំខាន់ៗរបស់វិស័យពាក់ព័ន្ធនឹង គ.ភ.ឃ.ស.។

**តារាងទី២២ ៖ សូចនាករ និងចំណុចដៅនៃលទ្ធផលរំពឹងទុក ២.៤.២.**

| ល.រ. | សូចនាករ | ដើមគ្រា | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|
| ១ | ការសិក្សាអំពីប្រព័ន្ធទិន្នន័យនានាដែលមានពាក់ព័ន្ធនឹង គ.ភ.ឃ.ស. | | | | | ១ | |
| ២ | ការកំណត់ជម្រើសសមស្របសម្រាប់ប្រព័ន្ធទិន្នន័យ គ.ភ.ឃ.ស. ថ្នាក់ជាតិ | | | | | | ១ |

## ៥. យន្តការសម្រាប់ការអនុវត្ត

ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្រោមការដឹកនាំ និងសម្របសម្រួលរបស់ក្រសួងមហាផ្ទៃ ដោយមានលេខាធិការដ្ឋាន គ.ភ.ឃ.ស. ជាជំនួយការក្នុងការគ្រប់គ្រង និងការអនុវត្តជាប្រចាំនូវផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។ ក្នុងន័យនេះ ក្រុមចំណុះទាំង៤នៃលេខាធិការដ្ឋាន គ.ភ.ឃ.ស. មានភារកិច្ចដឹកនាំ និងអនុវត្តយុទ្ធសាស្ត្រទាំង ៧ នៃផែនការយុទ្ធសាស្ត្រ ស្របតាមតួនាទី និងភារកិច្ចរបស់ខ្លួន ដោយត្រូវកំណត់ និងរៀបចំសកម្មភាពជាអាទិភាពដែលត្រូវអនុវត្តក្នុងឆ្នាំនីមួយៗ ដើម្បីបញ្ចូលក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស.។ ក្រុមរដ្ឋបាលសរុប និងភស្តុភារទទួលខុសត្រូវក្នុងការបូកសរុប និងរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់លេខាធិការដ្ឋានស្តីពីការអនុវត្ត គ.ភ.ឃ.ស. និងត្រូវជានាការវិភាជថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តផែនការនេះ។

ផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» នឹងចូលរួមអនុវត្តដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។

ក្រសួង ស្ថាប័ន ដោយមានក្រុមការងារ គ.ភ.ឃ.ស. ជាជំនួយការ ទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពជាអាទិភាពនានានៃលទ្ធផលរំពឹងទុកតាមយុទ្ធសាស្ត្រនីមួយៗ ដែលពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ ហើយសកម្មភាពទាំងនេះត្រូវបញ្ចូលក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់ក្រសួង ស្ថាប័ន។

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយមានលេខាធិការដ្ឋានជាជំនួយការ ទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពជាអាទិភាពនានានៃលទ្ធផលរំពឹងទុក តាមយុទ្ធសាស្ត្រនីមួយៗដែលពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់ខ្លួន ហើយសកម្មភាពទាំងនេះត្រូវបញ្ចូល ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់គណៈបញ្ជាការឯកភាព។

រដ្ឋបាលឃុំ សង្កាត់ ដោយមានការជួយគាំទ្រពីប៉ុស្តិ៍នគរបាលរដ្ឋបាល គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងអ្នកពាក់ព័ន្ធនានា ត្រូវអនុវត្តសកម្មភាពជាអាទិភាពនានានៃលទ្ធផលរំពឹងទុកតាមយុទ្ធសាស្ត្រនីមួយៗ ដែលពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់ខ្លួន ហើយសកម្មភាពទាំងនេះត្រូវបញ្ចូលក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់ឃុំ សង្កាត់។

លេខាធិការដ្ឋាន គ.ភ.ឃ.ស. ត្រូវលើកកម្ពស់ការសម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍ អង្គការ សង្គមស៊ីវិល ដើម្បីចូលរួម និងគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

## ៦. ការត្រួតពិនិត្យ និងការវាយតម្លៃ

ការត្រួតពិនិត្យ និងការវាយតម្លៃ គឺជាការកិច្ចការដ៏មានសារសំខាន់ ដើម្បីធានាថា សកម្មភាពជាអាទិភាពត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ស្របតាមពេលវេលា និងធនធានដែលបានកំណត់ និង

ឈានទៅសម្រេចបានលទ្ធផលរំពឹងទុក និងគោលដៅតាមផែនការគ្រោងទុក។

ក្របខណ្ឌលទ្ធផល គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្រ្តស្តីពីការអនុវត្ត គ.ភ.ឃ.ស. ដើម្បីធានាថា លទ្ធផលរំពឹងទុកនានាត្រូវបានអនុវត្ត និងសម្រេចដោគជ័យ ហើយជាលទ្ធផលនឹងនាំឱ្យសម្រេចបានគោលដៅ គោលបំណង និងចក្ខុវិស័យដែលបានកំណត់។

ក្រុមរដ្ឋបាលសរុប និងភស្តុភារ ត្រូវទទួលខុសត្រូវក្នុងការរៀបចំផែនការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្រ្តស្តីពីការអនុវត្ត គ.ភ.ឃ.ស. ដោយសហការជាមួយក្រុមនានាចំណុះលេខាធិការដ្ឋាន គ.ភ.ឃ.ស.។ សកម្មភាពនានានៃការត្រួតពិនិត្យ និងការវាយតម្លៃត្រូវបញ្ចូលក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់លេខាធិការដ្ឋាន។ ជាមួយគ្នានេះដែរ ក្រុមរដ្ឋបាលសរុប និងភស្តុភារក៏ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តនេះផងដែរ។

សកម្មភាពជាអាទិភាព និងវិធីសាស្រ្តសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តស្តីពីការអនុវត្ត គ.ភ.ឃ.ស. រួមមានដូចខាងក្រោម ៖

### ៦.១. ការរៀបចំទិន្នន័យដើមគ្រា

ដើម្បីជាមូលដ្ឋានសម្រាប់ការវាស់វែងវឌ្ឍនភាពនៃលទ្ធផលនានា ដែលបានកំណត់ក្នុងក្របខណ្ឌលទ្ធផលរបស់ផែនការយុទ្ធសាស្រ្តស្តីពីការអនុវត្ត គ.ភ.ឃ.ស. លេខាធិការដ្ឋាន គ.ភ.ឃ.ស. ត្រូវរៀបចំចងក្រងទិន្នន័យដើមគ្រាដោយផ្តោតលើសូចនាករសំខាន់ៗ និងចាំបាច់នានា តាមរយៈការប្រើប្រាស់ទិន្នន័យ និងព័ត៌មានដែលមានស្រាប់ ដូចជាប្រព័ន្ធទិន្នន័យស្តីពីការផ្តល់សេវា ប្រព័ន្ធទិន្នន័យគ្រប់គ្រងបទល្មើស ប្រព័ន្ធទិន្នន័យស្តីពីសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ របាយការណ៍ស្តីពីការវាយតម្លៃ និងឯកសារពាក់ព័ន្ធផ្សេងទៀត។

ការរៀបចំចងក្រងទិន្នន័យដើមគ្រា ត្រូវធ្វើឡើងក្នុងឆ្នាំទី១នៃផែនការយុទ្ធសាស្រ្ត។

### ៦.២. ការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ

នៅដំណាច់ឆ្នាំនីមួយៗ លេខាធិការដ្ឋាន គ.ភ.ឃ.ស. ត្រូវរៀបចំការវាយតម្លៃស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តស្តីពីការអនុវត្ត គ.ភ.ឃ.ស. ដោយផ្តោតជាសំខាន់លើលទ្ធផលដែលសម្រេចបានធៀបនឹងលទ្ធផលរំពឹងទុក និងសូចនាករដែលបានកំណត់ក្នុងឆ្នាំទី១នៃក្របខណ្ឌយុទ្ធសាស្រ្ត។ របាយការណ៍ស្តីពីការវាយតម្លៃនេះ ត្រូវបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស.។

### ៦.៣. ការវាយតម្លៃពាក់កណ្តាលផែនការ

ការវាយតម្លៃពាក់កណ្តាលផែនការ ឬការវាយតម្លៃពាក់កណ្តាលអាណត្តិ នឹងត្រូវអនុវត្តក្នុងឆ្នាំ ២០២៦ក្នុងគោលបំណងពិនិត្យមើលពីលទ្ធផលនានាដែលសម្រេចបាន និងកំណត់បញ្ហាប្រឈមនានាដែលជួបប្រទះក្នុងការអនុវត្តផែនការយុទ្ធសាស្រ្ត ធៀបនឹងក្របខណ្ឌលទ្ធផល។ ការវាយតម្លៃនេះត្រូវបញ្ចូលនូវអនុសាសន៍កែលម្អការអនុវត្ត និងលទ្ធផលរំពឹងទុកជាអាទិភាពដែលត្រូវសម្រេចក្នុងរយៈពេល២ឆ្នាំចុងក្រោយនៃផែនការយុទ្ធសាស្រ្ត។

## ៦.៤. ការវាយតម្លៃចុងបញ្ចប់នៃផែនការ

ការវាយតម្លៃចុងបញ្ចប់ផែនការ ត្រូវអនុវត្តនៅចុងឆ្នាំ២០២៨ ឬដើមឆ្នាំ២០២៩ ដើម្បីពិនិត្យមើលការសម្រេចបានលទ្ធផលនានា ដែលបានកំណត់នៅក្នុងក្របខណ្ឌលទ្ធផលនៃផែនការយុទ្ធសាស្ត្រ និងជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រដំណាក់កាលបន្ទាប់។ កម្រិតលទ្ធផលដែលត្រូវធ្វើការវាយតម្លៃរួមមាន ៖

- ចក្ខុវិស័យ
- គោលបំណង
- គោលដៅ
- លទ្ធផលរំពឹងទុក

លទ្ធផលនៃការវាយតម្លៃនេះ ក៏នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំទិន្នន័យដើមគ្រានៃផែនការយុទ្ធសាស្ត្រដំណាក់កាលបន្ទាប់។

## ៧. ការគ្រប់គ្រងហានិភ័យ

ការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» គឺជាការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធនានាទាំងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។ អាស្រ័យហេតុនេះ ការអនុវត្តគោលនយោបាយនេះ អាចជួបប្រទះនូវហានិភ័យមួយចំនួនដែលទាមទារឱ្យមានការសម្រុះសម្រួល និងដោះស្រាយឱ្យបានសមស្រប និងទាន់ពេលវេលា។ ហានិភ័យ និងវិធានការកាត់បន្ថយមានរៀបរាប់នៅក្នុងតារាងខាងក្រោម ៖

**តារាងទី២៣ ៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ**

| ល.រ. | ហានិភ័យ | ភាពអាចកើតមានឡើង | ផលប៉ះពាល់ | វិធានការបន្ធូរបន្ថយ |
|---|---|---|---|---|
| ១ | ការសម្របសម្រួល និងកិច្ចសហការមិនបានល្អរវាងក្រសួង ស្ថាប័នក្នុងការអនុវត្ត គ.ភ.ឃ.ស. នៅថ្នាក់ឃុំ សង្កាត់ ដូចជាការចុះតាមដាន និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំចលនាប្រឡងប្រណាំង | ទាប | ខ្ពស់ | – រៀបចំកិច្ចប្រជុំ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត គ.ភ.ឃ.ស.<br>– ពង្រឹងការសម្របសម្រួល និងកិច្ចសហការរវាងក្រសួង ស្ថាប័នក្នុងការអនុវត្ត គ.ភ.ឃ.ស. |
| ២ | ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនមិនបានរៀបចំសកម្មភាព និងវិភាជថវិកាជាក់លាក់សម្រាប់អនុវត្ត គ.ភ.ឃ.ស. | មធ្យម | ខ្ពស់ | – តាមដាន និងគាំទ្រក្រុមការងារក្រសួង ស្ថាប័នក្នុងការរៀបចំសកម្មភាព និងការវិភាជថវិកាសម្រាប់អនុវត្ត គ.ភ.ឃ.ស.<br>– សម្របសម្រួល និងសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រចាំ |

| ល.រ. | ហានិភ័យ | ភាពអាចកើតមានឡើង | ផលប៉ះពាល់ | វិធានការបន្ធូរបន្ថយ |
|---|---|---|---|---|
| | | | | ក្នុងការរៀបចំគម្រោងថវិកាសម្រាប់អនុវត្ត គ.ភ.ឃ.ស. |
| ៣ | រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌមួយចំនួនពុំបានរៀបចំសកម្មភាព និងវិភាជថវិកាដាក់លាក់សម្រាប់អនុវត្ត គ.ភ.ឃ.ស. | មធ្យម | ខ្ពស់ | – តាមដាន និងគាំទ្រក្រុមការងារក្រសួងស្ថាប័នក្នុងការរៀបចំសកម្មភាព និងការវិភាជថវិកាសម្រាប់អនុវត្ត គ.ភ.ឃ.ស.<br>– សម្របសម្រួល និងសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រចាំក្នុងការរៀបចំគម្រោងថវិកាសម្រាប់អនុវត្ត គ.ភ.ឃ.ស. |
| ៤ | ខ្វះការចូលរួមពីអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការអនុវត្ត គ.ភ.ឃ.ស. | មធ្យម | មធ្យម | – លើកកម្ពស់ការផ្សព្វផ្សាយយុទ្ធសាស្ត្រស្តីពីភាពជាដៃគូ<br>– រៀបចំកិច្ចប្រជុំជាប្រចាំ និងទៀងទាត់សម្របសម្រួលជាមួយ តំណាងអង្គការសង្គមស៊ីវិល និងវិស័យឯកជននានា |
| ៥ | វិបត្តិសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោកនាំឱ្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានត្រូវបានកាត់បន្ថយ | ទាប | ខ្ពស់ | – ពិនិត្យ និងកែសម្រួលផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដោយផ្តោតលើសេវា និងគម្រោង សកម្មភាពដែលចាំបាច់បំផុត និងមានអាទិភាពខ្ពស់ |
| ៦ | ការកើតមានឡើងនៃជំងឺឆ្លងរាតត្បាតកាចសាហាវនានាដូចជា ជំងឺកូវីដ-១៩ នាំឱ្យការអនុវត្ត គ.ភ.ឃ.ស. មានភាពយឺតយ៉ាវ និងមានថវិកាមិនគ្រប់គ្រាន់ | ទាប | ខ្ពស់ | – ពិនិត្យ និងកែសម្រួលផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដោយផ្តោតគម្រោងសកម្មភាពដែលពាក់ព័ន្ធនឹងការការពារ ទប់ស្កាត់ និងព្យាបាលជំងឺ |
| ៧ | ការកើតមានគ្រោះមហន្តរាយធ្ងន់ធ្ងរនាំឱ្យការផ្តល់សេវាសាធារណៈត្រូវបានកាត់បន្ថយ ឬអាក់ខាន | ទាប | ខ្ពស់ | – ពិនិត្យ និងកែសម្រួលផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដោយផ្តោតលើគម្រោង សកម្មភាពដែលពាក់ព័ន្ធនឹងការគាំទ្រផលប៉ះពាល់ដែលបង្ករឡើងដោយគ្រោះមហន្តរាយ |

## ៨. គម្រោងថវិកា

ការប៉ាន់ស្មានចំណាយសរុបនៃផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានធ្វើឡើងផ្អែកលើសកម្មភាពជាអាទិភាពនានាដែលបានកំណត់ក្នុងលទ្ធផលរំពឹងទុកនីមួយៗ។ ជារួម ចំណាយទាំងនេះរួមមានចំណាយសម្រាប់ការរៀបចំលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងសៀវភៅណែនាំនានា ការផ្សព្វផ្សាយ ការអភិវឌ្ឍសមត្ថភាព ការរៀបចំសិក្ខាសាលា ឬកិច្ចប្រជុំនានា ការសិក្សា ការវាយតម្លៃ និងការរៀបចំឯកសារនានា ការរៀបចំប្រព័ន្ធទិន្នន័យ ការរៀបចំទស្សនកិច្ចសិក្សា ការចុះបេសកកម្ម និង

ចំណាយប្រតិបត្តិការពាក់ព័ន្ធផ្សេងទៀត។

ថវិកាសម្រាប់គាំទ្រចំណាយទាំងនេះ គឺជាការទទួលខុសរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។ ក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រ លេខាធិការដ្ឋាន គ.ភ.ឃ.ស. នឹងសហការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា ព្រមទាំងកៀរគរធនធានថវិកា និងបច្ចេកទេស ដើម្បីគាំទ្រផែនការនេះ។

ថវិកាប៉ាន់ស្មានសរុបនៃផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល៥ឆ្នាំពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ មានចំនួន ៥.៤៥៣ លានរៀល ស្មើនឹង ១,៣៦ លានដុល្លារអាមេរិក និងជាមធ្យមត្រូវការថវិកាចំនួន ១.១០០លានរៀល ស្មើនឹង ២៧០.០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ ។

**តារាងទី២៤ ៖ ថវិកាប៉ាន់ស្មាននៃផែនការយុទ្ធសាស្ត្រ**

*(គិតជាលានរៀល)*

| ល.រ. | យុទ្ធសាស្ត្រ | ថវិកាប៉ាន់ស្មានតាមយុទ្ធសាស្ត្រ និងតាមឆ្នាំ | | | | | សរុប | % |
|---|---|---|---|---|---|---|---|---|
| | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | | |
| ១ | ការពង្រឹងយន្តការ គ.ភ.ឃ.ស. | ២៨៣ | ២៣៩ | ២៥៩ | ២៣៩ | ២៣៩ | **១,២៦១** | ២៣.១២% |
| ២ | ការរៀបចំលិខិតបទដ្ឋាន | ៨២ | ១២២ | ១១០ | ១១០ | ១១០ | **៥៣៤** | ៩.៧៩% |
| ៣ | ការអភិវឌ្ឍសមត្ថភាព | ១៥២ | ៣៤៤ | ១៥២ | ២៨៤ | ១៥២ | **១,០៨៤** | ១៩.៨៨% |
| ៤ | ការលើកកម្ពស់ការអនុវត្ត គ.ភ.ឃ.ស. | ២៥៨ | ១៣៨ | ១៩៨ | ២៥៨ | ១៩៨ | **១,២៥០** | ២២.៩២% |
| ៥ | ការលើកកម្ពស់ភាពជាដៃគូ | ៦៣ | ២២ | ២ | ២ | ២ | **៩១** | ១.៦៨% |
| ៦ | ការជំរុញចលនាប្រលងប្រណាំង | ១១៨ | ៤៨ | ១១៨ | ២៥៨ | ១២៨ | **៦៧០** | ១២.២៩% |
| ៧ | ការពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ២១០ | ២២ | ២២ | ១៦៧ | ១៤២ | **៥៦៣** | ១០.៣២% |
| | **សរុប** | **១,១៦៧** | **៩៣៥** | **៨៦១** | **១,៣១៨** | **៩៧១** | **៥,៤៥៣** | **១០០%** |

## ៩. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្ត គ.ភ.ឃ.ស. គឺជាផែនទីបង្ហាញផ្លូវសម្រាប់ក្រសួងមហាផ្ទៃក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០២៤ដល់ឆ្នាំ២០២៨ ក្នុងនាមជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្ត គ.ភ.ឃ.ស. ប្រកបដោយជោគជ័យ។ ផែនការនេះផ្តោតជាសំខាន់លើការពង្រឹងរចនាសម្ព័ន្ធ និងសមត្ថភាពនៃយន្តការអនុវត្ត គ.ភ.ឃ.ស. ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការរៀបចំលិខិតបទដ្ឋាន ការលើកកម្ពស់ការកសាងផែនការ និងការវិភាជថវិកាសម្រាប់អនុវត្ត គ.ភ.ឃ.ស.។ ជាមួយគ្នានេះដែរ ផែនការយុទ្ធសាស្ត្រក៏យកចិត្តទុកដាក់លើកិច្ចសហការជាមួយកម្មវិធីកំណែទម្រង់នានា និងភាពជាដៃគូ ជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា។ អាស្រ័យហេតុនេះ ស្ថាប័នអនុវត្តទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងការកសាងផែនការសកម្មភាព និងវិភាជថវិការបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រការអនុវត្ត គ.ភ.ឃ.ស. ប្រកបដោយប្រសិទ្ធភាព។

ក្រសួងមហាផ្ទៃមានជំនឿជឿជាក់ថា ផែនការយុទ្ធសាស្ត្រស្ដីពីការអនុវត្ត គ.ភ.ឃ.ស. របស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. នឹងសម្រេចបានលទ្ធផលនានាតាមការគ្រោងទុក ដើម្បីរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់ គ.ភ.ឃ.ស. គឺ "ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈប្រកបដោយគុណភាព តម្លាភាព បរិយាប័ន្នសង្គម និងរស់នៅប្រកបដោយសុវត្ថិភាព ផាសុកភាព និងសុខដុមរមនាក្នុងសហគមន៍ដែលមានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម បរិស្ថាន ធនធានធម្មជាតិ និងអនាម័យល្អប្រសើរ"។

# ឧបសម្ព័ន្ធទី១ ៖ ក្របខណ្ឌលទ្ធផលនៃផែនការយុទ្ធសាស្ត្រ

| | លទ្ធផល | សូចនាករ | ដើមគ្រា | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| | **ចក្ខុវិស័យ ៖**<br>ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈប្រកបដោយគុណភាព តម្លាភាព បរិយាប័ន្នសង្គម និងរស់នៅប្រកបដោយសុវត្ថិភាព ផាសុខភាព និងសុខដុមរមនាក្នុងសហគមន៍ដែលមានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម បរិស្ថាន ធនធានធម្មជាតិ និងអនាម័យល្អប្រសើរ។ | | | | | | | |
| | | | | | | | | |
| | **គោលបំណង ៖**<br>លើកកម្ពស់ការផ្តល់សេវាសាធារណៈ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់នានា ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ។ | | | | | | | |
| | | | | | | | | |
| | **គោលដៅទី១៖**<br>កសាង និងពង្រឹងសមត្ថភាពស្ថាប័ន និងបុគ្គលិកនៃលេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានាក្នុងការសម្របសម្រួល តាមដាន និងអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹង គ.ភ.ឃ.ស.។ | | | | | | | |
| | | | | | | | | |

| | លទ្ធផល | សូចនាករ | ដើមគ្រា | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| | **យុទ្ធសាស្ត្រទី ១.១ ៖**<br>ពង្រឹងយន្តការដឹកនាំ សម្របសម្រួល និងអនុវត្ត គ.ភ.ឃ.ស. | | | | | | | |
| | **លទ្ធផលរំពឹងទុក ១.១.១ ៖**<br>ការបំពេញតួនាទី និងភារកិច្ចរបស់ក្រសួងមហាផ្ទៃ ជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្ត គ.ភ.ឃ.ស.ត្រូវបានពង្រឹង | 1. ចំនួនកិច្ចប្រជុំដែលបានរៀបចំ | | ២ | ២ | ២ | ២ | ២ |
| | | 2. ការរៀបចំរបាយការណ៍ជូនក្រសួងមហាផ្ទៃ | | ១ | ១ | ១ | ១ | ១ |
| | | 3. ការរៀបចំរបាយការណ៍ជូនរាជរដ្ឋាភិបាល | | ១ | ១ | ១ | ១ | ១ |
| | **លទ្ធផលរំពឹងទុក ១.១.២ ៖**<br>ការបំពេញតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. ដើម្បីជួយ ក្រសួងមហាផ្ទៃអនុវត្ត គ.ភ.ឃ.ស. ត្រូវបានពង្រឹង | 4. ការរៀបចំក្រុមជំនួយការ | | ១ | | | | |
| | | 5. ការរៀបចំក្រុមបច្ចេកទេស | | ១ | | | | |
| | | 6. កិច្ចប្រជុំរបស់លេខាធិការដ្ឋាន | | ៤ | ៤ | ៤ | ៤ | ៤ |
| | | 7. កិច្ចប្រជុំជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | | ៤ | ៤ | ៤ | ៤ | ៤ |
| | | 8. ចំនួនលិខិតបទដ្ឋានដែលបានរៀបចំ | | ២ | ២ | ២ | ២ | ២ |
| | | 9. ចំនួនវគ្គដែលបានរៀបចំ | | ៣ | ៣ | ៣ | ៣ | ៣ |
| | **លទ្ធផលរំពឹងទុក ១.១.៣ ៖**<br>ក្រុមការងារ គ.ភ.ឃ.ស. របស់ក្រសួង ស្ថាប័ន ត្រូវបានបង្កើត និងដំណើរការ | 10. ការរៀបចំលក្ខខណ្ឌក្រុមការងារ | | ១ | | | | |
| | | 11. ការបង្កើតក្រុមការងារ | | ១ | | | | |
| | | 12. គាំទ្រ និងអភិវឌ្ឍសមត្ថភាពក្រុមការងារ | | ២ | ២ | ២ | ២ | ២ |
| | **លទ្ធផលរំពឹងទុក ១.១.៤ ៖**<br>ការបំពេញតួនាទី និងភារកិច្ចរបស់គណៈបញ្ជាការឯកភាពរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានពង្រឹង | 13. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំ | | ៣ | ៣ | ៣ | ៣ | ៣ |
| | | 14. ភាគរយគណៈបញ្ជាការឯកភាពក្រុង ស្រុក ខណ្ឌ ខេត្តដែលបានគាំទ្រ | | ៥០% | ៧០% | ៧០% | ៧០% | ៧០% |
| | | 15. ភាគរយគណៈបញ្ជាការឯកភាពដែលមាន ពិនិត្យ និងកែសម្រួលសមាសភាព | | ៣០% | ៥០% | ១០០% | ១០០% | ១០០% |
| | **លទ្ធផលរំពឹងទុក ១.១.៥ ៖**<br>ការបំពេញតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវបានពង្រឹង | 16. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំ | | ៣ | ៣ | ៣ | ៣ | ៣ |
| | | 17. ភាគរយលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរាជធានី ខេត្តដែលបានគាំទ្រ | | ៥០% | ៧០% | ៧០% | ៧០% | ៧០% |
| | | 18. ភាគរយលេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពក្រុង ស្រុក ខណ្ឌ ខេត្តដែលបានគាំទ្រ | | ២០% | ៣០% | ៥០% | ៥០% | ៥០% |

| | លទ្ធផល | សូចនាករ | ដើមគ្រា | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| | | 19. ភាគរយរដ្ឋបាលឃុំ សង្កាត់ដែលបានគាំទ្រ | | ២0% | ៣0% | ៥0% | ៥0% | ៥0% |
| | **លទ្ធផលពឹងទុក ១.១.៦ ៖** ការបំពេញតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធនឹងការអនុវត្ត គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានពង្រឹង | 20. ភាគរយឃុំ សង្កាត់ដែលបានគាំទ្រក្នុងការអនុវត្ត គ.ភ.ឃ.ស. | | ២0% | ៣0% | ៥0% | ៥0% | ៥0% |
| | | 21. ការសិក្សា និងរៀបចំយន្តការ គ.ភ.ឃ.ស. នៅថ្នាក់ឃុំ សង្កាត់ | | | ១ | | | |
| | **លទ្ធផលពឹងទុក ១.១.៧ ៖** កិច្ចសហការរវាងគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ជាមួយកម្មវិធីកំណែទម្រង់នានា ត្រូវបានលើកកម្ពស់ | 22. សេចក្តីសង្ខេបអំពី គ.ភ.ឃ.ស. | | ១ | | | | |
| | | 23. ការចូលរួមកិច្ចប្រជុំកំណែទម្រង់៣បូក១ | | ៤ | ៤ | ៤ | ៤ | ៤ |
| | | 24. ចំនួនលិខិតបទដ្ឋានដែលបានរៀបចំ | | ២ | ២ | ២ | ២ | ២ |
| | **យុទ្ធសាស្ត្រទី ១.២ ៖** រៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការអនុវត្ត គ.ភ.ឃ.ស. | | | | | | | |
| | **លទ្ធផលពឹងទុក ១.២.១ ៖** លិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងឯកសារបច្ចេកទេសចាំបាច់នានាពាក់ព័ន្ធនឹង គ.ភ.ឃ.ស. ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | 25. ការរៀបចំបញ្ជីលិខិតបទដ្ឋានដែលត្រូវរៀបចំ និងដាក់ចេញ | | ១ | ១ | ១ | ១ | ១ |
| | | 26. ចំនួនលិខិតបទដ្ឋានដែលបានរៀបចំ និងដាក់ចេញ | | ៣ | ៣ | ៣ | ៣ | ៣ |
| | **លទ្ធផលពឹងទុក ១.២.២ ៖** លិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងឯកសារបច្ចេកទេសដែលបានដាក់ ចេញ ត្រូវបានផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពដល់ភាគីពាក់ព័ន្ធនានា | 27. បញ្ជីលិខិតបទដ្ឋានដែលបានរៀបចំ | | ១ | ១ | ១ | ១ | ១ |
| | | 28. វិធីសាស្ត្រ ឯកសារ និងសម្ភារបានរៀបចំ | | ១ | ១ | ១ | ១ | ១ |
| | | 29. ចំនួនការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល | | ៣ | ៣ | ៣ | ៣ | ៣ |
| | **យុទ្ធសាស្ត្រទី ១.៣ ៖** លើកកម្ពស់ចំណេះដឹង និងសមត្ថភាពអំពី គ.ភ.ឃ.ស. | | | | | | | |

| | លទ្ធផល | សូចនាករ | ដើមគ្រា | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| | **លទ្ធផលរំពឹងទុក ១.៣.១ ៖** សមត្ថភាពរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្នុងការសម្របសម្រួល ត្រួតពិនិត្យ និងគាំទ្រការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានអភិវឌ្ឍ | 30. ផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ | | ១ | ១ | ១ | ១ | ១ |
| | | 31. ទស្សនកិច្ចសិក្សា | | | ១ | | ១ | |
| | | 32. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាព | | | ១ | | | |
| | **លទ្ធផលរំពឹងទុក ១.៣.២ ៖** ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានាមានចំណេះដឹង និងសមត្ថភាពច្បាស់លាស់អំពី គ.ភ.ឃ.ស. | 33. ការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | | ១ | ១ | ១ | ១ | ១ |
| | | 34. ផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ | | ១ | ១ | ១ | ១ | ១ |
| | | 35. ទស្សនកិច្ចសិក្សា | | ១ | | ១ | | ១ |
| | **លទ្ធផលរំពឹងទុក ១.៣.៣ ៖** ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាមានការយល់ដឹង ច្បាស់លាស់អំពី គ.ភ.ឃ.ស. | 36. ចំនួនការផ្សព្វផ្សាយប្រចាំឆ្នាំស្ដីពី គ.ភ.ឃ.ស. | | ២ | ៣ | ៣ | ៣ | ៣ |
| | | 37. ចំនួនវេទិកាសាធារណៈដែលបានរៀបចំ | | ៤ | ៤ | ៤ | ៤ | ៤ |
| | | 38. ភាគរយសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋដែលបានដោះស្រាយ | | ៧០% | ៧០% | ៧០% | ៧០% | ៧០% |
| | **គោលដៅទី២៖** លើកកម្ពស់ការអនុវត្ត គ.ភ.ឃ.ស. ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព មានសមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម និងក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។ | | | | | | | |
| | | | | | | | | |
| | **យុទ្ធសាស្ត្រទី ២.១ ៖** គោលនយោបាយ គ.ភ.ឃ.ស. ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព | | | | | | | |
| | **លទ្ធផលរំពឹងទុក ២.១.១ ៖** | 39. ការរៀបចំវិធីសាស្ត្រ និងឧបករណ៍នានា សម្រាប់បញ្ចូល គ.ភ.ឃ.ស. ក្នុងផែនការ | | ១ | | | | |

| | លទ្ធផល | សូចនាករ | ដើមគ្រា | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| | លក្ខណសម្បត្តិទាំង ៧ នៃ គ.ភ.ឃ.ស. ត្រូវបាន រៀបចំ និងបញ្ចូលក្នុងផែនការ និងថវិការបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា | 40. ភាគរយក្រសួង ស្ថាប័នដែលបានបញ្ចូលសកម្មភាពនៃ គ.ភ.ឃ.ស. ក្នុងផែនការរបស់ខ្លួន | | ៥0% | ៧0% | ៩0% | ១00% | ១00% |
| | | 41. ភាគរយរាជធានី ខេត្តដែលបានបញ្ចូលសកម្មភាពនៃ គ.ភ.ឃ.ស. ក្នុងផែនការរបស់ខ្លួន | | ៥0% | ៧0% | ៩0% | ១00% | ១00% |
| | | 42. ភាគរយក្រុង ស្រុក ខណ្ឌដែលបានបញ្ចូលសកម្មភាពនៃ គ.ភ.ឃ.ស. ក្នុងផែនការរបស់ខ្លួន | | ៥0% | ៧0% | ៩0% | ១00% | ១00% |
| | | 43. ភាគរយឃុំ សង្កាត់ដែលបានបញ្ចូលសកម្មភាពនៃ គ.ភ.ឃ.ស. ក្នុងផែនការរបស់ខ្លួន | | ១00% | ១00% | ១00% | ១00% | ១00% |
| | **លទ្ធផលរំពឹងទុក ២.១.២ ៖** ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់ស្ថាប័នទទួលខុសត្រូវត្រូវបានរៀបចំ និងអនុវត្តប្រកបដោយប្រសិទ្ធភាព | 44. ការរៀបចំ និងចេញការណែនាំដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | | ១ | ១ | ១ | ១ | ១ |
| | | 45. ភាគរយក្រសួង ស្ថាប័ន ដែលបានរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | | ៥0% | ៧0% | ៩0% | ១00% | ១00% |
| | | 46. ភាគរយរាជធានី ខេត្តដែលបានរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | | ៥0% | ១00% | ១00% | ១00% | ១00% |
| | | 47. ភាគរយក្រុង ស្រុក ខណ្ឌ ដែលបានរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | | ៥0% | ៧0% | ១00% | ១00% | ១00% |
| | | 48. ភាគរយឃុំ សង្កាត់ ដែលបានរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. | | ៥0% | ៧0% | ១00% | ១00% | ១00% |
| | **លទ្ធផលរំពឹងទុក ២.១.៣៖** ការត្រួតពិនិត្យ និងគាំទ្រការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់ស្ថាប័នអនុវត្ត | 49. ភាគរយក្រសួង ស្ថាប័នដែលបានគាំទ្រក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្ត គ.ភ.ឃ.ស. | | ៦0% | ៧0% | ៧0% | ៧0% | ៧0% |
| | | 50. ភាគរយរាជធានី ខេត្តដែលបានគាំទ្រក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្ត គ.ភ.ឃ.ស. | | ៥0% | ៥0% | ៥0% | ៥0% | ៥0% |
| | | 51. កិច្ចប្រជុំប្រចាំត្រីមាសដែលបានរៀបចំ | | ៤ | ៤ | ៤ | ៤ | ៤ |
| | | 52. ការរៀបចំរបាយការណ៍ដែលបានរៀបចំ | | ២ | ២ | ២ | ២ | ២ |

| | លទ្ធផល | សូចនាករ | ដើមគ្រា | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| | **លទ្ធផលរំពឹងទុក ២.១.៤ ៖** ការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្ត គ.ភ.ឃ.ស. និង គ.ភ.ឃ.ស. របស់រាជរដ្ឋាភិបាល | 53. ការរៀបចំទិន្នន័យដើមគ្រា | | ១ | | | | |
| | | 54. ការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ | | ១ | ១ | ១ | ១ | ១ |
| | | 55. ការវាយតម្លៃពាក់កណ្តាលផែនការ | | | | ១ | | |
| | | 56. ការវាយតម្លៃចុងបញ្ចប់ផែនការ | | | | | | ១ |
| | | 57. ការវាយតម្លៃការអនុវត្ត គ.ភ.ឃ.ស. | | | | | ១ | |
| | **យុទ្ធសាស្ត្រទី ២.២ ៖** លើកកម្ពស់ភាពជាដៃគូក្នុងការអនុវត្ត គ.ភ.ឃ.ស. | | | | | | | |
| | **លទ្ធផលរំពឹងទុក ២.២.១៖** យុទ្ធសាស្ត្រស្តីពីភាពជាដៃគូសម្រាប់អនុវត្ត គ.ភ.ឃ.ស. ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | 58. ការសិក្សា និងរៀបចំយុទ្ធសាស្ត្រស្តីពីភាពជាដៃគូ | | ១ | | | | |
| | | 59. ការអនុម័ត និងផ្សព្វផ្សាយយុទ្ធសាស្ត្រស្តីពីភាពជាដៃគូ | | | ១ | | | |
| | | 60. គម្រោង កម្មវិធីនានាគាំទ្រដោយដៃគូស្តីពីការអនុវត្ត គ.ភ.ឃ.ស. | | | | ១ | ២ | ២ |
| | **លទ្ធផលរំពឹងទុក ២.២.២៖** យន្តការភាពជាដៃគូសម្រាប់អនុវត្ត គ.ភ.ឃ.ស. ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ ដើម្បីសម្របសម្រួលជាមួយដៃគូនានា | 61. ការបង្កើតក្រុមការងារ | | ១ | | | | |
| | | 62. ការរៀបចំកិច្ចប្រជុំក្រុមការងារ | | ១ | ២ | ២ | ២ | ២ |
| | **យុទ្ធសាស្ត្រទី ២.៣ ៖** ជំរុញចលនាប្រលងប្រណាំងស្តីពីការអនុវត្ត គ.ភ.ឃ.ស. | | | | | | | |
| | **លទ្ធផលរំពឹងទុក ២.៣.១៖** ចលនាប្រលងប្រណាំងការអនុវត្ត គ.ភ.ឃ.ស. តាមវិស័យជំនាញនីមួយៗ ត្រូវបានពិនិត្យ កែសម្រួល និងលើកកម្ពស់ | 63. ការពិនិត្យមើលឡើងវិញអំពីចលនាប្រលងប្រណាំងដែលបានអនុវត្ត | | ១ | | | | |
| | | 64. ការដាក់ចេញសេចក្តីណែនាំរួមអំពីចលនាប្រលងប្រណាំងដែលបានអនុវត្ត | | ១ | | | | |
| | | 65. ចលនាប្រលងប្រណាំងដែលបានអនុវត្ត ស្របតាមសេចក្តីណែនាំដែលបានកែសម្រួល | | | ២ | ៣ | ៥ | ៥ |
| | **លទ្ធផលរំពឹងទុក ២.៣.២៖** គោលនយោបាយលើកទឹកចិត្តស្តីពីការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានរៀបចំ | 66. ការពិនិត្យមើលឡើងវិញ | | | | ១ | | |
| | | 67. ទស្សនកិច្ចសិក្សាក្នុងតំបន់ | | | | | ១ | |
| | | 68. គោលនយោបាយលើកទឹកចិត្ត | | | | | | ១ |

| | លទ្ធផល | សូចនាករ | ដើមគ្រា | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| | **យុទ្ធសាស្ត្រទី ២.៤ ៖** ពង្រឹងប្រព័ន្ធទិន្នន័យសម្រាប់អនុវត្ត និងគ្រប់គ្រង គ.ភ.ឃ.ស. តាមរយៈប្រព័ន្ធឌីជីថល | | | | | | | |
| | **លទ្ធផលរំពឹងទុក ២.៤.១៖** ការអនុវត្តលក្ខណសម្បត្តិនានានៃ គ.ភ.ឃ.ស. ត្រូវបានពង្រឹង តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | 69. គាំទ្រឧបករណ៍ និងសម្ភារៈព័ត៌មានវិទ្យាដល់ថ្នាក់ដឹកនាំ និងបុគ្គលិកលេខាធិការដ្ឋាន គ.ភ.ឃ.ស. | | ១ | | | | |
| | | 70. បង្កើត និងគាំទ្រប្រព័ន្ធអ៊ិនធឺណែត | | ១ | | | | |
| | | 71. ភាគរយក្រុង ស្រុកមានប្រព័ន្ធអ៊ិនធឺណែត | | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| | | 72. ភាគរយឃុំ សង្កាត់មានប្រព័ន្ធអ៊ិនធឺណែត | | | | | | |
| | | 73. ចំនួនវិស័យដែលបានផ្តល់សេវាតាមប្រព័ន្ធអនឡាញ | | ៥ | ៦ | ៧ | ១០ | ១៥ |
| | | 74. ចំនួនប្រព័ន្ធទិន្នន័យសម្រាប់គ្រប់គ្រង គ.ភ.ឃ.ស. ដែលបានបង្កើត | | | | | | |
| | **លទ្ធផលរំពឹងទុក ២.៤.២៖** ប្រព័ន្ធទិន្នន័យថ្នាក់ជាតិសម្រាប់ការគ្រប់គ្រង គ.ភ.ឃ.ស. ត្រូវបានរៀបចំ | 75. ការសិក្សាអំពីប្រព័ន្ធទិន្នន័យនានា | | | | | ១ | |
| | | 76. ការកំណត់ជម្រើសសមស្រប | | | | | | ១ |

**ឧបសម្ព័ន្ធទី២ ៖ ថវិកាប៉ាន់ស្មានតាមយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុកពីឆ្នាំ២០២៤-២០២៨ (គិតជាលានរៀល)**

| **កូដ** | **យុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក** | **ថវិកាប៉ាន់ស្មានតាមឆ្នាំ** | | | | | |
|---|---|---|---|---|---|---|---|
| | | **២០២៤** | **២០២៥** | **២០២៦** | **២០២៧** | **២០២៨** | **សរុប** |
| **១.១** | **ការពង្រឹងយន្តការ គ.ភ.ឃ.ស. ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន** | ២៨៣ | ២៣៩ | ២៥៩ | ២៣៩ | ២៣៩ | ១,២៦១ |
| ១.១.១ | ការបំពេញតួនាទី និងភារកិច្ចរបស់ក្រសួងមហាផ្ទៃក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានពង្រឹង | ៤១ | ៤១ | ៤១ | ៤១ | ៤១ | ២០៥ |
| ១.១.២ | ការបំពេញតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. ដើម្បីជួយ ក្រសួងមហាផ្ទៃ អនុវត្ត គ.ភ.ឃ.ស. ត្រូវបានពង្រឹង | ៣៥ | ៣៤ | ៣៤ | ៣៤ | ៣៤ | ១៧៣ |
| ១.១.៣ | ក្រុមការងារ គ.ភ.ឃ.ស. របស់ក្រសួង ស្ថាប័ន ត្រូវបានបង្កើត និងដំណើរការ | ៣ | ០ | ០ | ០ | ០ | ៣ |
| ១.១.៤ | ការបំពេញតួនាទី និងភារកិច្ចរបស់គណៈបញ្ជាការឯកភាពរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានពង្រឹង | ៤០ | ៤០ | ៦០ | ៤០ | ៤០ | ២២០ |
| ១.១.៥ | ការបំពេញតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃគណៈបញ្ជាការឯកភាពរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវបានពង្រឹង | ៧៨ | ៧៨ | ៧៨ | ៧៨ | ៧៨ | ៣៩០ |
| ១.១.៦ | ការបំពេញតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធនឹងការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានពង្រឹង | ៧០ | ៣០ | ៣០ | ៣០ | ៣០ | ១៩០ |
| ១.១.៧ | កិច្ចសហការរវាងគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ជាមួយកម្មវិធីកំណែទម្រង់នានា ត្រូវបានលើកកម្ពស់ | ១៦ | ១៦ | ១៦ | ១៦ | ១៦ | ៨០ |
| **១.២** | **ការរៀបចំ និងដាក់ចេញលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាពាក់ព័ន្ធនឹង គ.ភ.ឃ.ស.** | ៨២ | ១២២ | ១១០ | ១១០ | ១១០ | ៥៣៤ |
| ១.២.១ | លិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងឯកសារបច្ចេកទេសចាំបាច់នានាពាក់ព័ន្ធនឹង គ.ភ.ឃ.ស. ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ៨២ | ៨២ | ៨២ | ៨២ | ៨២ | 410 |

| កូដ | យុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក | ថវិកាប៉ាន់ស្មានតាមឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | សរុប |
| ១.២.២ | លិខិតបទដ្ឋានគតិយុត្ត និងឯកសារបច្ចេកទេសដែលបានដាក់ចេញ ត្រូវបានផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពដល់ភាគីពាក់ព័ន្ធនានា | ០ | ៤០ | ២៨ | ២៨ | ២៨ | ១២៤ |
| **១.៣** | **ការលើកកម្ពស់ចំណេះដឹង និងសមត្ថភាពអំពី គ.ភ.ឃ.ស.** | ១៥២ | ៣៨៤ | ១៥២ | ២៨៤ | ១៥២ | ១,០៨៤ |
| ១.៣.១ | សមត្ថភាពរបស់លេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្នុងការសម្របសម្រួល ត្រួតពិនិត្យ និងគាំទ្រការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានអភិវឌ្ឍ | ៣៤ | ១៩៤ | ៣៤ | ១៣៤ | ៣៤ | ៤៣០ |
| ១.៣.២ | ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានាមានចំណេះដឹង និងសមត្ថភាពច្បាស់លាស់អំពី គ.ភ.ឃ.ស. | ៨៨ | ១០៨ | ៨៨ | ១០៨ | ៨៨ | ៤៨០ |
| ១.៣.៣ | ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាមានការយល់ដឹង ច្បាស់លាស់អំពី គ.ភ.ឃ.ស. | ៣០ | ៤២ | ៣០ | ៤២ | ៣០ | ១៧៤ |
| **២.១** | **ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត គ.ភ.ឃ.ស.** | ២៥៨ | ១៣៨ | ១៩៨ | ២៥៨ | ១៩៨ | ១,២៥០ |
| ២.១.១ | លក្ខណសម្បត្តិទាំង ៧ នៃ គ.ភ.ឃ.ស. ត្រូវបានរៀបចំ និងបញ្ចូលក្នុងផែនការ និងថវិការបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា | ៦០ | ២០ | ២០ | ២០ | ២០ | ១៤០ |
| ២.១.២ | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់ស្ថាប័ន ទទួលខុសត្រូវ ត្រូវបានរៀបចំ និងអនុវត្ត | ២០ | ២០ | ២០ | ២០ | ២០ | ១០០ |
| ២.១.៣ | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្ត គ.ភ.ឃ.ស. របស់ស្ថាប័នទទួលខុសត្រូវ ត្រូវបានរៀបចំ និងអនុវត្ត | ៧០ | ៧០ | ៧០ | ៧០ | ៧០ | ៥៥០ |
| ២.១.៤ | ការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រស្តីពីការអនុវត្ត គ.ភ.ឃ.ស. និង គ.ភ.ឃ.ស. | ១០៨ | ២៨ | ៨៨ | ១៤៨ | ៨៨ | ៤៦០ |
| **២.២** | **ការលើកកម្ពស់ភាពជាដៃគូក្នុងការអនុវត្ត គ.ភ.ឃ.ស.** | ៦៣ | ២២ | ២ | ២ | ២ | ៩១ |

| កូដ | យុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក | ថវិកាប៉ាន់ស្មានតាមឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | សរុប |
| ២.២.១ | យុទ្ធសាស្ត្រស្ដីពីភាពជាដៃគូសម្រាប់អនុវត្ត គ.ភ.ឃ.ស. ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ៦០ | ២០ | ០ | ០ | ០ | ៨០ |
| ២.២.២ | យន្តការភាពជាដៃគូសម្រាប់អនុវត្ត គ.ភ.ឃ.ស. ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ ដើម្បីសម្របសម្រួលជាមួយដៃគូនានា | ៣ | ២ | ២ | ២ | ២ | ១១ |
| **២.៣** | **ការជំរុញចលនាប្រលងប្រណាំងស្ដីពីការអនុវត្ត គ.ភ.ឃ.ស.** | ១១៨ | ៤៨ | ១១៨ | ២៥៨ | ១២៨ | ៦៧០ |
| ២.៣.១ | ចលនាប្រលងប្រណាំងការអនុវត្ត គ.ភ.ឃ.ស. តាមវិស័យជំនាញនីមួយៗ ត្រូវបានពិនិត្យកែសម្រួល និងលើកកម្ពស់ | ១១៨ | ៤៨ | ៤៨ | ៤៨ | ៤៨ | ៣១០ |
| ២.៣.២ | គោលនយោបាយលើកទឹកចិត្តស្ដីពីការអនុវត្ត គ.ភ.ឃ.ស. ត្រូវបានរៀបចំ | ០ | ០ | ៧០ | ២១០ | ៨០ | ៣៦០ |
| **២.៤** | **ពង្រឹងប្រព័ន្ធទិន្នន័យសម្រាប់អនុវត្ត និងគ្រប់គ្រង គ.ភ.ឃ.ស. តាមរយៈប្រព័ន្ធឌីជីថល** | ២១០ | ២២ | ២២ | ១៦៧ | ១៤២ | ៥៦៣ |
| ២.៤.១ | ការអនុវត្តលក្ខណសម្បត្តិនានានៃ គ.ភ.ឃ.ស. ត្រូវបានពង្រឹង តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | ២១០ | ២២ | ២២ | ៦៧ | ២២ | ៣៤៣ |
| ២.៤.២ | ប្រព័ន្ធទិន្នន័យថ្នាក់ជាតិសម្រាប់ការគ្រប់គ្រង គ.ភ.ឃ.ស. ត្រូវបានរៀបចំ | ០ | ០ | ០ | ១០០ | ១២០ | ២២០ |
| | **សរុបរួម** | ១,១៦៧ | ៩៣៥ | ៨៦១ | ១,៣១៨ | ៩៧១ | ៥,៤៥៣ |

**ឧបសម្ព័ន្ធទី៣ ៖ រចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.គ.ឃ.ស.**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០១ គនស

# គោលនយោបាយ

# «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀត មានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីយើងមានសន្តិភាព ស្ថិរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខមាលភាពរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាចាំបាច់នានា នៅតែជាបញ្ហាអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឱ្យជនគ្រប់រូប និងសង្គមទាំងមូល មានសុវត្ថិភាពយ៉ាងល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។

ឆ្លងកាត់បទពិសោធន៍អស់រយៈពេល១០ឆ្នាំ ក្រសួងមហាផ្ទៃដោយមានការគាំទ្រ និងចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋាន និងអ្នកពាក់ព័ន្ធ បានចាត់តាំងអនុវត្តប្រកបដោយជោគជ័យ និងបានធ្វើការកែលម្អផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» ជាបន្តបន្ទាប់ ឱ្យស្របតាមបរិបទនៃការអភិវឌ្ឍរីកចម្រើនរបស់សង្គមជាតិ។

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន និងកៀរគរឱ្យមានការចូលរួមគាំទ្រកាន់តែច្រើនថែមទៀត រាជរដ្ឋាភិបាលសម្រេចកែលម្អលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងលើកកម្រិតគោលនយោបាយនេះជារបស់រាជរដ្ឋាភិបាល ដែលមានគោលបំណង និងសំណូមពរ ដូចខាងក្រោម៖

១. បន្តកសាង និងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

២. កសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដោយបំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។

I. លក្ខណសម្បត្តិរបស់ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។

២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។

៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។

៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព។

៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ។

៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយនិងរាល់ជំងឺឆ្លងពាក់ព័ន្ធកាចសាហាវប្រកបដោយប្រសិទ្ធភាព ។

II. វិធានការជាមូលដ្ឋាន

លក្ខណសម្បត្តិទាំង០៧យ៉ាង នៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានចាត់តាំងអនុវត្តតាមវិធានការជាមូលដ្ឋានដូចខាងក្រោមៈ

១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្តៈ

ចាត់វិធានការឱ្យបានហ្មត់ចត់ និងទាន់ពេលវេលាក្នុងការលើកកម្ពស់ការផ្តល់សេវារដ្ឋបាល សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននានានៅគ្រប់វិស័យ នៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ទាំងផ្នែកបរិមាណ គុណភាព ប្រសិទ្ធភាព តម្លាភាព ពោលគឺជំរុញឱ្យការផ្តល់សេវា និងកិច្ចអន្តរាគមន៍នានាកាន់តែកៀកកិតនឹងប្រជាពលរដ្ឋ សំដៅបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋកាន់តែច្រើនឡើង។

២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទៈ

-ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ និងយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំអំពីច្បាប់ពាក់ព័ន្ធ និងផលប៉ះពាល់នានាដែលបណ្តាលមកពីបទល្មើសគ្រប់ប្រភេទ ជាពិសេសអំពើ លួច ឆក់ ប្លន់ ចាប់ជំរិតយកប្រាក់ ការប្រើប្រាស់អាវុធខុសច្បាប់ និងល្បែង

ស៊ីសងខុសច្បាប់ ព្រមទាំងបទល្មើសធនធានធម្មជាតិ និងបរិស្ថាន ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់។

- ត្រូវចាត់វិធានការក្នុងការបង្ការ ទប់ស្កាត់ឱ្យបានជាអតិបរមានូវការចរាចរ ការចែកចាយ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ព្រមទាំងខិតខំលុបបំបាត់ការដាំដុះ ការរក្សាទុក ការលួចកែច្នៃសារធាតុញៀនគ្រប់ប្រភេទតាមគ្រប់រូបភាពនៅតាមភូមិ ឃុំ សង្កាត់។

- ត្រូវជំរុញបំផុសចលនាអប់រំមហាជនដើម្បីចូលរួមបង្ការ ទប់ស្កាត់បទល្មើសគ្រឿងញៀនគ្រប់ប្រភេទ ជាពិសេសអនុវត្តឱ្យបានទូលំទូលាយនូវខ្លឹមសារទិសស្លោក «បីកុំ-មួយរាយការណ៍» ៖

❖ **បីកុំ ៖**

- **កុំរោភ់ព័ន្ធ** ៖ កុំជួញដូរ កុំចែកចាយ កុំធ្វើខ្នងបង្អែក កុំឃុបឃិតនិងកុំប្រើប្រាស់គ្រឿងញៀន។
- **កុំអន្តរាគមន៍** ៖ កុំរាំងការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន ទោះបីជាក្រុមគ្រួសារ សាច់ញាតិ ឬមិត្តភ័ក្រក៏ដោយ។
- **កុំលើកលែង** ៖ កុំបន្ធូរបន្ថយការអនុវត្តច្បាប់ចំពោះឧក្រិដ្ឋជនគ្រឿងញៀន ។ សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ និងស្មោះត្រង់វិជ្ជាជីវៈរបស់ខ្លួន ហើយជនគ្រប់រូបត្រូវគោរព និងអនុវត្តច្បាប់។

❖ **មួយរាយការណ៍៖** ត្រូវរាយការណ៍ ផ្តល់ព័ត៌មានដល់សមត្ថកិច្ចអំពីមុខសញ្ញាជួញដូរ ចែកចាយ ប្រើប្រាស់ ទីតាំងកែច្នៃ ផលិត និងទីតាំងស្តុកទុកគ្រឿងញៀន។

- ត្រូវសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ អនុវត្តតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន យុទ្ធសាស្ត្រទាំង០៥ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន បទបញ្ជា សារាចរណែនាំ និងផែនការយុទ្ធនាការក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាលតាមគ្រប់ដំណាក់កាល។

- ត្រូវជំរុញឱ្យមានការបំផុសចលនាចូលរួមសហការ គាំទ្រពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ។

## ៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍

- ជំរុញការរឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋាននានា ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមា នូវហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ រួមទាំងអ្នកស្លាប់ និងរបួស ដោយត្រូវចាត់តាំងអនុវត្តឱ្យបានម៉ឺងម៉ាត់ តាមផែនការយុទ្ធនាការរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងផែនការសកម្មភាពរបស់អនុគណៈកម្មការទី២ នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

- ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ នៅទីប្រជុំជន តំបន់ផ្សារ នៅលើដងផ្លូវ និងតាមចិញ្ចើមផ្លូវ ដើម្បីសម្រួលដល់ការធ្វើដំណើរទៅមករបស់អ្នកប្រើប្រាស់ផ្លូវ និងជាពិសេសរួមចំណែកដល់ការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ដែលបណ្តាលមកពីគ្មានសណ្តាប់ធ្នាប់សាធារណៈ។

**៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង៖**

- ចាត់វិធានការឱ្យបានជាអតិបរមាដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់អំពើអនាចារ អំពើរំលោភសេពសន្ថវៈ ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ អំពើហិង្សាក្នុងគ្រួសារដើម្បីការពារសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋឱ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ ដោយអនុវត្តឱ្យបានហ្មត់ចត់តាមច្បាប់ និងផែនការយុទ្ធសាស្ត្រជាតិរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

- ត្រូវចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ ឃុំ សង្កាត់ល្អប្រសើរ ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់ និងជាប្រចាំ តាមស្មារតីនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាល សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ និងផែនការ សកម្មភាពរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពាក់ព័ន្ធដល់វិធានការក្នុងការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង។

**៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព ៖**

- ពង្រឹងការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទនៅមូលដ្ឋាន នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ព្រមទាំងពង្រឹងសមត្ថភាព និងបច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ សំដៅលើកកម្ពស់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការតាមយន្តការផ្សះផ្សា ឬសម្របសម្រួលដែលកំណត់ដោយក្រសួងយុត្តិធម៌។

- ខិតខំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ ជាពិសេសភាគីវិវាទ ឱ្យយល់អំពីខ្លឹមសារ និងសារសំខាន់នៃយន្តការ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងគោលដៅកាត់បន្ថយការកកស្ទះសំណុំរឿងនៅស្ថាប័នតុលាការ ការខាតបង់ពេលវេលា ថវិកាផ្ទាល់ខ្លួននិងការចំណាយថវិការដ្ឋ ព្រមទាំងបង្កើតភាពសុខដុមរមនាក្នុងសង្គម។

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ ៖**

- មានវិធានការក្នុងការគ្រប់គ្រង ថែរក្សា និងការពារធនធានធម្មជាតិ និងបរិស្ថាន អនាម័យក្នុងភូមិ ឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព ជាពិសេសយន្តការដោះស្រាយបញ្ហាសំរាម សំណល់រឹង និងសំណល់រាវ សំដៅធ្វើឱ្យភូមិ ឃុំ សង្កាត់ មានសោភ័ណភាព គ្មានសំរាម ធ្វើឱ្យការរស់នៅប្រកបដោយផាសុកភាព មានភាពថ្លៃថ្នូរ ស៊ីវិល័យ និងមានអនាគតរុងរឿង ផ្អែកតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ។

- បញ្ជ្រាបការអប់រំដល់ប្រជាពលរដ្ឋ អំពីច្បាប់ គោលការណ៍ និងវិធានការនានា ស្តីពីកិច្ចការពារថែរក្សាបរិស្ថាន រួមទាំងវិធីសាស្ត្រនៃការរក្សាសុខភាព ការចូលរួមថែរក្សាអនាម័យ សុវត្ថិភាពចំណីអាហារ ឧទាហរណ៍៖ ការផលិតស្រាខុសបទដ្ឋានបច្ចេកទេស ការចែកចាយ លក់ដូរ និងប្រើប្រាស់ថ្នាំពេទ្យ គ្រឿងសម្អាង... ក្លែងក្លាយ ឬអត់គុណភាព។

៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព៖

- រួមគ្នាចាត់វិធានការឆ្លើយតប និងផ្តល់ព័ត៌មានត្រឡប់ឱ្យបានទាន់ពេលវេលា ក្នុងការកាត់បន្ថយនូវហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានាដែលកើតមានឡើងនៅក្នុងមូលដ្ឋាន ឧទាហរណ៍៖ ជំងឺកូវីដ-១៩...។

- ត្រូវបំផុសចលនាមហាជនដើម្បីចូលរួមនៅក្នុងការបង្ការ ទប់ស្កាត់ ការពារជំងឺឆ្លងរាតត្បាតកាចសាហាវ និងគ្រោះមហន្តរាយដែលបាននិងបម្រុងកើតឡើងជាយថាហេតុ។

III. ផែនការសកម្មភាព

១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព និងតម្លាភាពទទួលបានជំនឿទុកចិត្ត៖

- យកចិត្តទុកដាក់លើកកម្ពស់ក្នុងការផ្តល់សេវាសាធារណៈចាំបាច់ និងជាមូលដ្ឋាន រួមមាន ការអប់រំ សុខាភិបាល ផ្លូវគមនាគមន៍ ទឹកស្អាត អគ្គិសនី និងសេវាសាធារណៈចាំបាច់ដទៃទៀតដែលពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងសមធម៌។

- ពង្រឹង និងពង្រីកការអនុវត្តតួនាទីរបស់ការិយាល័យច្រកចេញ-ចូលតែមួយ និងយន្តការច្រកចេញ-ចូលតែមួយ លើការងារផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរថែមទៀត។ រៀបចំឱ្យមានអ្នកទទួលខុសត្រូវច្បាស់លាស់ក្នុងការប្រចាំការដោះស្រាយការស្នើសុំសេវានានារបស់ប្រជាពលរដ្ឋ ឱ្យបានទាន់ពេលវេលា ឆាប់រហ័ស មានប្រសិទ្ធភាព និងតម្លាភាព។

២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ៖

- ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ បញ្ជាដឹកនាំការអនុវត្តផែនការប្រយុទ្ធប្រឆាំងបទល្មើសពិសេស អំពើលួច ឆក់ ប្លន់ ចាប់ជំរិតទារប្រាក់នៅតាមភូមិ ឃុំ សង្កាត់។

- លើកកម្ពស់គុណភាព និងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ សំដៅបង្កើនប្រសិទ្ធភាពក្នុងការស្រាវជ្រាវស៊ើបអង្កេត ព្រមទាំងជំរុញសកម្មភាពតាមចាប់មុខសញ្ញា និងអនុវត្តដីកាដែលសេសសល់ ។

- តាមដាន ត្រួតពិនិត្យ និងដឹកនាំតម្រង់ទិសដល់នគរបាលប៉ុស្តិ៍រដ្ឋបាល ក្នុងការអនុវត្តការងារតាមបែបនគរបាលនិងសហគមន៍។

- យកចិត្តទុកដាក់គាំទ្រដល់ប៉ុស្តិ៍នគរបាលរដ្ឋបាល ទាំងស្មារតី សម្ភារ ការពង្រឹងសមត្ថភាព ដើម្បីមានលទ្ធភាពក្នុងការគ្រប់គ្រងស្ថានការណ៍សន្តិសុខ សណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់។

- ពង្រឹងប្រជាការពារ ដើម្បីចូលរួមក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន និងលើកកម្ពស់កិច្ចសហការជាមួយកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើតឱ្យមានយន្តការផ្លាស់ប្តូរព័ត៌មាន និងគាំទ្រគ្នាទៅវិញទៅមក ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ។

- រៀបចំផែនការបង្ការ ទប់ស្កាត់ បង្ក្រាប សកម្មភាពលួចនាំសារធាតុញៀនខុសច្បាប់គ្រប់ប្រភេទ តាមច្រកព្រំដែន និងច្រករបៀងនៃប្រទេសជិតខាងចូលមកកម្ពុជា និងការរក្សាទុក ឬលួចកែច្នៃសារធាតុញៀនសំយោគគ្រប់ប្រភេទ។

- ជំរុញសកម្មភាពក្នុងការអនុវត្តវិធានការរដ្ឋបាលស្របជាមួយនឹងវិធានការច្បាប់ ក្នុងការស្រាវជ្រាវតាមដាន ត្រួតពិនិត្យ ការលួចជួញដូរ និងប្រើប្រាស់សារធាតុញៀននៅតាមទីតាំងសប្បាយដ្ឋាននានា និងនៅតាមភូមិ ឃុំ សង្កាត់។

- ជំរុញការផ្សព្វផ្សាយអប់រំនៅតាមសហគមន៍ តាមសាលារៀន និងបញ្ជ្រាបការអប់រំនៅតាមពិធីផ្សេងៗដែលប្រារព្ធធ្វើឡើងនៅតាមមូលដ្ឋាន អំពីគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន។

- ខិតខំស្រាវជ្រាវ និងបង្ក្រាបឱ្យបានការលួចដាំដុះដំណាំដែលមានសារធាតុញៀននៅគ្រប់ភូមិសាស្ត្រ។

- បង្កើនការផ្លាស់ប្តូរព័ត៌មានជាមួយដៃគូជាតិ អន្តរជាតិ សំដៅម្ចាស់ការក្នុងការបង្ការ ទប់ស្កាត់ពីចម្ងាយ និងសហការស្រាវជ្រាវកាត់ផ្តាច់ខ្សែរយៈ និងជាពិសេសតាមចាប់មេខ្លោងមកផ្តន្ទាទោសតាមច្បាប់។

### ៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍

- បង្កើនការអប់រំ ផ្សព្វផ្សាយអំពីច្បាប់ និងផលប៉ះពាល់នានាដែលបណ្តាលមកពីការមិនគោរពច្បាប់ចរាចរណ៍ផ្លូវគោក ដោយត្រូវមានវិធីសាស្ត្រផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព មានជាអាទិ៍ កម្មវិធីសាសនា សិល្បៈ កម្មវិធីអភិវឌ្ឍន៍ វេទិកាសាធារណៈ និងកម្មវិធីផ្សេងៗក្នុងសង្គម។

- រៀបចំសណ្តាប់ធ្នាប់ឱ្យបានល្អនៅតំបន់មានផ្សារ ទីប្រជុំជន សាលារៀន និងតំបន់ស្មុគស្មាញនានា ត្រូវហាមឃាត់ការដាក់តាំងលក់ទំនិញនៅលើដងផ្លូវ ការចតយានយន្តគ្រប់ប្រភេទដែលធ្វើឱ្យប៉ះពាល់ដល់ការធ្វើចរាចរ។ ចំពោះទីតាំងធ្វើអាជីវកម្ម សេវាកម្ម ត្រូវរៀបចំឱ្យមានចំណតសម្រាប់មធ្យោបាយនិងយានយន្តគ្រប់ប្រភេទ ដើម្បីបញ្ចៀសនូវការកកស្ទះចរាចរណ៍ និងការបាត់បង់សណ្តាប់ធ្នាប់។ ត្រូវមានវិធានការរៀបចំសណ្តាប់ធ្នាប់ និងការឆ្លងកាត់ផ្លូវរបស់សិស្សានុសិស្សពេលម៉ោងចេញ-ចូលសាលារៀន។

### ៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង

- បង្កើនសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ទាំងបច្ចេកទេសប្រតិបត្តិការ និងនីតិវិធីក្នុងការស្រាវជ្រាវ ស៊ើបអង្កេតប្រយុទ្ធប្រឆាំងអំពើអនាចារ ការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ។

- ខិតខំជំរុញសកម្មភាពស្រាវជ្រាវ ស៊ើបអង្កេតរកមេខ្លោងពាក់ព័ន្ធដល់អំពើជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ ព្រមទាំងសកម្មភាពជួញដូរតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប។

- សហការជាមួយស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីជំរុញសកម្មភាពផ្សព្វផ្សាយអប់រំការជួយសង្គ្រោះ និងស្តារនីតិសម្បទាដល់ជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស។

- ពង្រឹងការគ្រប់គ្រង និងស្រាវជ្រាវតាមទីតាំងអាជីវកម្ម សេវាកម្មដែលលួចប្រព្រឹត្តអំពើអនាចារ និងការជួញដូរផ្លូវភេទ។

- ពង្រឹងយន្តការសហប្រតិបត្តិការជាមួយដៃគូជាតិ អន្តរជាតិ ក្នុងការផ្លាស់ប្តូរព័ត៌មាននានា ពាក់ព័ន្ធដល់សភាពការណ៍ បណ្តាញឧក្រិដ្ឋជន ព្រមទាំងព័ត៌មានដទៃផ្សេងទៀត ពាក់ព័ន្ធដល់ជនរងគ្រោះនៅក្រៅប្រទេស។

- មានកម្មវិធីច្បាស់លាស់ក្នុងការរៀបចំវេទិកាផ្សព្វផ្សាយអប់រំអំពីគុណធម៌ សីលធម៌ វប្បធម៌ និងច្បាប់ពាក់ព័ន្ធ សំដៅកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងសកម្មភាពក្មេងទំនើងនៅតាមភូមិ ឃុំ សង្កាត់។

### ៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព

- ខិតខំបង្កើនសមត្ថភាព ចំណេះដឹង និងជំនាញបន្ថែមទៀតដល់អ្នកទទួលសិទ្ធិក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទទួលបាននូវយន្តការផ្សេងៗដែលសមស្របទៅនឹងវិធានច្បាប់ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ កាន់តែទទួលបាននូវជំនឿទុកចិត្តពីប្រជាពលរដ្ឋ។

- ត្រូវខិតខំពង្រឹងអព្យាក្រឹតភាព វិជ្ជាជីវៈរបស់អ្នកសម្របសម្រួល ឱ្យប្រកាន់ខ្ជាប់នូវភាពមិនលំអៀង រក្សាការសម្ងាត់ ដើម្បីបង្កើនភាពជឿជាក់ដល់ភាគីវិវាទ។

- អ្នកសម្របសម្រួល ត្រូវធ្វើកំណត់ហេតុនៃការដោះស្រាយ និងជូនព័ត៌មានអំពីលទ្ធផលនៃដំណោះស្រាយរបស់គូវិវាទ ដែលទទួលយកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការឱ្យបានលឿន និងចំណេញពេលវេលា ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅបានជ្រាប។

### ៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ

- បង្កើនការតាមដាន ត្រួតពិនិត្យនៅតាមទីតាំងសាធារណៈ អំពីការគ្រប់គ្រងអនាម័យ បរិស្ថាន ឈរលើគោលការណ៍ «ការរស់នៅស្អាត ភូមិឋានស្អាត សុខភាពល្អ ជីវិតរីករាយ អនាគតរុងរឿង»។

- ទប់ស្កាត់ និងឆ្លើយតបឱ្យបានទាន់ពេលវេលានូវគ្រោះថ្នាក់ដែលបណ្តាលមកពីការពុលចំណីអាហារ និងភេសជ្ជៈនានា ជាពិសេសត្រូវមានការត្រួតពិនិត្យតាំងពីដើមទី ទាំងការនាំចូល ការដាំដុះ និងការផលិត។

- មានផែនការបង្ការ ទប់ស្កាត់ឱ្យបានទាន់ពេលវេលា នូវសកម្មភាពលួចកាប់បំផ្លាញ និងទន្ទ្រានទីតាំងព្រៃឈើនៅក្នុងសហគមន៍ និងសហការជាមួយឧទ្យានុរក្សដើម្បីបង្ការ និងទប់ស្កាត់ការកាប់ទន្ទ្រាននៅតាមតំបន់ការពារធម្មជាតិ។

### ៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតអាចសាយភាយប្រកបដោយប្រសិទ្ធភាព

មានផែនការម្ចាស់ការទុកជាមុនក្នុងការសង្គ្រោះបឋមជួយដល់អាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានា។ ត្រូវអប់រំអំពីវិធីការពារ ទប់ស្កាត់ជំងឺឆ្លងរាតត្បាតដែលមានហានិភ័យខ្ពស់ វិធីបង្ការគ្រោះថ្នាក់បណ្តាលមកពីគ្រោះមហន្តរាយ តាមវិធានការនានាដែលកំណត់ដោយក្រសួងជំនាញ។

## IV. ការចាត់តាំងអនុវត្ត

១. ក្រសួងមហាផ្ទៃធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលដោយត្រូវ៖

- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ព្រមទាំងដឹកនាំតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿន គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

- បង្កើតលេខាធិការដ្ឋានដើម្បីរៀបចំផែនការសកម្មភាព និងតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿនក្នុងការអនុវត្តលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងបូកសរុបវាយតម្លៃ រាយការណ៍តាមដំណាក់កាលនីមួយៗ ជូនរាជរដ្ឋាភិបាលអំពីលទ្ធផលនៃការចាត់តាំងអនុវត្តគោលនយោបាយនេះ។

២. ក្រសួង ស្ថាប័ននានាចំណុះរាជរដ្ឋាភិបាល ត្រូវរៀបចំក្រុមការងារដើម្បីជួយក្នុងការរៀបចំផែនការសកម្មភាព និងជួយតាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿនក្នុងការអនុវត្តលក្ខណសម្បត្តិ នៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលមានការពាក់ព័ន្ធទៅនឹងវិស័យជំនាញរបស់ក្រសួង ស្ថាប័ននីមួយៗ និងត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តជូនមកលេខាធិការដ្ឋានក្រសួងមហាផ្ទៃតាមកាលកំណត់។

៣. ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមឱ្យបានសកម្ម គាំទ្ររដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ក្នុងការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ឱ្យទទួលបានជោគជ័យ។

៤. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំផែនការ និងវិធានការជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងទទួលខុសត្រូវដឹកនាំផ្ទាល់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយត្រូវ៖

- រៀបចំលេខាធិការដ្ឋានដោយមានអង្គភាពនគរបាលធ្វើជាសេនាធិការ និងមានសមាសភាពមកពីមន្ទីរ អង្គភាពពាក់ព័ន្ធនានា ព្រមទាំងរៀបចំឱ្យមានក្រុមការងារចុះជួយតាមមូលដ្ឋានឃុំ សង្កាត់ ដោយយកភូមិជាគោលដៅ ដើម្បីសហការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។
- ជំរុញការផ្សព្វផ្សាយ និងបំផុសចលនាមហាជន ព្រមទាំងផ្នែកពាក់ព័ន្ធ ដើម្បីសហការ និងចូលរួមគាំទ្រ ក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

- រដ្ឋបាលឃុំ សង្កាត់ត្រូវដាក់បញ្ចូលការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិល ព្រមទាំងក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីជួយគាំទ្រ និងជំរុញការអនុវត្តឱ្យទទួលបានជោគជ័យ។

៥. នគរបាលប៉ុស្តិ៍រដ្ឋបាល មានតួនាទីស្នូលក្នុងការចាត់ចែងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយត្រូវៈ

- អនុវត្តឱ្យបានខ្ជាប់ខ្ជួន នូវតួនាទី ភារកិច្ច និងតាមទម្រង់នៃការងារនគរបាលនិងសហគមន៍

- ដឹកនាំពង្រឹងកម្លាំងប្រជាការពារ និងធ្វើការផ្សព្វផ្សាយបំផុសចលនាមហាជន រួមទាំងផ្នែកពាក់ព័ន្ធ ដើម្បីចូលរួមក្នុងចលនាអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

- ត្រូវមានកិច្ចសហការ ទំនាក់ទំនងជាមួយកងកម្លាំងសមត្ថកិច្ចនានា ដែលបោះទីតាំងនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឱ្យមានយន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមកក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសគ្រប់ប្រភេទ ការរៀបចំអនាម័យ បរិស្ថាន កាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីជំងឺឆ្លងរាតត្បាតកាចសាហាវ និងគ្រោះមហន្តរាយនានាក្នុងភូមិ ឃុំ សង្កាត់។

៦. វេទិកាសាធារណៈ និងការផ្សព្វផ្សាយៈ

ត្រូវរៀបចំឱ្យមានវេទិកាសាធារណៈ និងវេទិកាផ្សព្វផ្សាយអំពីគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដើម្បីបញ្ជ្រាបការយល់ដឹង និងបំផុសឱ្យមានការសហការ ចូលរួមគាំទ្រពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋនៅទូទាំងប្រទេសៈ

- ការរៀបចំវេទិកាសាធារណៈ គួរខិតខំរៀបចំឱ្យបានញឹកញាប់តាមរូបភាពតូចៗ យ៉ាងហោចណាស់ក្នុង០១ខែ ឱ្យបានម្តង ដោយក្នុងវេទិកានេះ ត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធទៅនឹងលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» និងត្រូវខិតខំដោះស្រាយរាល់បញ្ហាប្រឈមនានាដែលបានលើកឡើង ព្រមទាំងផ្តល់ព័ត៌មានឆ្លើយតបឱ្យបានសមស្របជូនប្រជាពលរដ្ឋវិញ។ ក្នុងករណីដោះស្រាយមិនបាន ត្រូវរាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីមានវិធានការដោះស្រាយបន្ត។

- ការផ្សព្វផ្សាយគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» គួររៀបចំឱ្យបានញឹកញាប់តាមរូបភាពតូចៗជាក់ស្តែងទៅតាមភូមិសាស្ត្រនីមួយៗ សំដៅផ្សព្វផ្សាយចំគោលដៅ មុខសញ្ញា និងបង្កលក្ខណៈដល់អ្នកចូលរួមមានឱកាសបំពេញមុខរបរផង និងអាចទទួលបានការផ្សព្វផ្សាយដោយផ្ទាល់ផងដែរ។

៧. ការប្រឡងប្រណាំងៈ

ត្រូវចាត់តាំងឱ្យមានចលនាប្រឡងប្រណាំងបង្កើតស្នាដៃប្រចាំឆ្នាំនីមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញកាតព្វកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្ត គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ។

៨. គ្រប់ក្រសួង ស្ថាប័ន និងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ត្រូវចាត់តាំងប្រជុំបូកសរុប រយៈពេលយ៉ាងយូរ០៦ខែម្តង ដើម្បីមានមូលដ្ឋានក្នុងការវាយតម្លៃ ដកពិសោធន៍ និងដាក់ចេញទិសដៅអនុវត្តបន្ត។

ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើមកលេខាធិការដ្ឋានក្រសួងមហាផ្ទៃ។

៩. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃអង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

១០.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានការគិតគូរគ្រោងថវិកាសម្រាប់អនុវត្តផែនការសកម្មភាពពាក់ព័ន្ធនឹងគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» នៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាមីក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗ។

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានយកទៅផ្សព្វផ្សាយទូលំទូលាយទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋដើម្បីយល់ជ្រួតជ្រាប និងចូលរួមគាំទ្រអនុវត្តប្រកបដោយជោគជ័យ។

ថ្ងៃ អង្គារ ១៣ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សម្តេច ឯកឧត្តម លោកជំទាវប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានរាជធានី ខេត្ត
-គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ អាជ្ញាធរ គ្រឹះស្ថានសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិ
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ : ១០៧ ត.ប៉.ស.ជ.ប

ថ្ងៃព្រហស្បតិ៍ ៧កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២១

ក្រសួងមហាផ្ទៃ
ប្រទះ ... 388 ... 22.02.21

ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សូមជម្រាបជូន

-សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
-ឯកឧត្តមនាយឧត្តមសេនីយ៍ ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន
-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌
-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល

10.03.2021

**កម្មវត្ថុ ៖** ករណីសំណើសុំគោលការណ៍ដឹកនាំអំពីការអនុវត្តចលនាប្រលងប្រណាំងគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"។

**យោង ៖** -លិខិតលេខ១៧៣ លស ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ
-លិខិតលេខ០៧៣ ខន/០២១ សជណ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនសម្តេច ឯកឧត្តមមេត្តាជ្រាបថា រាជរដ្ឋាភិបាលយល់ព្រមជាគោលការណ៍ប្រគល់ភារកិច្ចដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលការណ៍ យន្តការ និងលក្ខណៈវិនិច្ឆ័យនានា សម្រាប់ចលនាប្រលងប្រណាំងអនុវត្តលក្ខណសម្បត្តិនៃគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព" ស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចខាងក្រោម៖

១-ក្រសួង ស្ថាប័ននានាដែលមានសមត្ថកិច្ចពាក់ព័ន្ធការផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាល ដែលជាលក្ខណសម្បត្តិទី១ នៃគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព" ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវចលនាប្រលងប្រណាំងលើការផ្តល់សេវាសាធារណៈ ដែលស្ថិតក្រោមសមត្ថកិច្ចទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននីមួយៗ។

២-ក្រសួងមហាផ្ទៃបន្តដឹកនាំចលនាប្រលងប្រណាំងពាក់ព័ន្ធការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៅមូលដ្ឋាន ដែលជាលក្ខណសម្បត្តិទី២ ទី៣ និងទី៤ នៃគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព" ព្រមទាំងចូលរួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា រៀបចំចលនាប្រលងប្រណាំងពាក់ព័ន្ធការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅថ្នាក់ក្រោមជាតិ ដែលជាលក្ខណសម្បត្តិទី១ នៃគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"។ ទន្ទឹមនឹងនេះ ក្រសួងមហាផ្ទៃក៏មានភារកិច្ចសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការរៀបចំលេខាធិការដ្ឋាន សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយនេះ ដើម្បីបូកសរុបរបាយការណ៍ជូនរាជរដ្ឋាភិបាល។

៣-ក្រសួងយុត្តិធម៌ដឹកនាំចលនាប្រលងប្រណាំងពាក់ព័ន្ធនឹងការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដែលជាលក្ខណសម្បត្តិទី៥ នៃគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"។

៤-ក្រសួងបរិស្ថានដឹកនាំចលនាប្រលងប្រណាំងពាក់ព័ន្ធនឹងអនាម័យ សោភ័ណភាព បរិស្ថាន ដែលជាលក្ខណសម្បត្តិទី៦ នៃគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"។

៥-ក្រសួងសុខាភិបាល និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដឹកនាំចលនាប្រលងប្រណាំងពាក់ព័ន្ធនឹងការឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ដែលជាលក្ខណសម្បត្តិទី៧ នៃគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"។

សេចក្តីដូចបានជម្រាបជូនខាងលើសូមសម្តេច ឯកឧត្តមមេត្តាជ្រាបនិងចាត់ចែងអនុវត្ត។

ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

កែន សត្ថា

**ចម្លងជូន៖**
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

# ផែនការយុទ្ធសាស្ត្រ គ.ភ.ឃ.ស.

## ២០២៤ - ២០២៨

### ចក្ខុវិស័យ

ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈប្រកបដោយគុណភាព តម្លាភាព បរិយាប័ន្នសង្គម និងរស់នៅប្រកបដោយសុវត្ថិភាព ផាសុកភាព និងសុខដុមរមនាក្នុងសហគមន៍ដែលមានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម បរិស្ថាន ធនធានធម្មជាតិ និងអនាម័យល្អប្រសើរ។

### គោលបំណង

លើកកម្ពស់ការផ្តល់សេវាសាធារណៈ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់ អនាម័យ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់នានា ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ។

### គោលដៅ

១. កសាង និងពង្រឹងសមត្ថភាពស្ថាប័ន និងបុគ្គលិកនៃលេខាធិការដ្ឋាន គ.ភ.ឃ.ស. ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ភាគីពាក់ព័ន្ធនានាក្នុងការសម្របសម្រួល តាមដាន និងអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹង គ.ភ.ឃ.ស.។

២. លើកកម្ពស់ការអនុវត្ត គ.ភ.ឃ.ស. ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព មានសមភាពយេនឌ័រ បរិយាប័ន្ន សមធម៌សង្គម និងក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។

### យុទ្ធសាស្ត្រចំនួន ៧

| យុទ្ធសាស្ត្រ ទី១ | យុទ្ធសាស្ត្រ ទី២ | យុទ្ធសាស្ត្រ ទី៣ | យុទ្ធសាស្ត្រ ទី៤ | យុទ្ធសាស្ត្រ ទី៥ | យុទ្ធសាស្ត្រ ទី៦ | យុទ្ធសាស្ត្រ ទី៧ |
|---|---|---|---|---|---|---|
| ពង្រឹងយន្តការដឹកនាំ សម្របសម្រួល និងអនុវត្ត គ.ភ.ឃ.ស. | រៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងឯកសារបច្ចេកទេសនានា ពាក់ព័ន្ធនឹងការអនុវត្ត គ.ភ.ឃ.ស. | លើកកម្ពស់ចំណេះដឹង និងសមត្ថភាពអំពី គ.ភ.ឃ.ស. | គោលនយោបាយ គ.ភ.ឃ.ស. ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព | លើកកម្ពស់ភាពជាដៃគូក្នុងការអនុវត្ត គ.ភ.ឃ.ស. | ជំរុញចលនាប្រឡងប្រណាំងស្តីពីការអនុវត្ត គ.ភ.ឃ.ស. | ពង្រឹងប្រព័ន្ធទិន្នន័យសម្រាប់អនុវត្ត និងគ្រប់គ្រង គ.ភ.ឃ.ស. តាមរយៈប្រព័ន្ធឌីជីថល |

### ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ៖

ការរៀបចំទិន្នន័យដើម → ការវាយតម្លៃប្រចាំឆ្នាំ → ការវាយតម្លៃពាក់កណ្តាល → ការវាយតម្លៃចុងបញ្ចប់

ស្កេនដើម្បីទាញយកឯកសារផែនការយុទ្ធសាស្ត្រ គ.ភ.ឃ.ស.